

របាយការណ៍ស្រាវជ្រាវ

# ម.១៣

## មន្ទីរសន្តិសុខខ្មែរក្រហមក្នុងសម័យសង្គ្រាម ( ១៩៧០-១៩៧៥ )


គាំទ្រដោយ៖

ឧបត្ថម្ភដោយ៖ KONRAD ADENAUER STIFTUNG

រៀបចំដោយ៖

9 789924 574019 >


KONRAD ADENAUER STIFTUNG

# របាយការណ៍ស្រាវជ្រាវ

**មន្ទីរ១៣(ម-១៣)៖ មន្ទីរសន្តិសុខខ្មែរក្រហមក្នុងសម័យសង្គ្រាម(១៩៧០-១៩៧៥)**

រៀបចំដោយ៖ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង
គាំទ្រដោយ៖ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
ឧបត្ថម្ភដោយ៖ មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ ប្រចាំប្រទេសកម្ពុជា

សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង
អាសយដ្ឋាន៖ ផ្លូវ១១៣កែង៣៥០ សង្កាត់បឹងកេងកង៣ ខណ្ឌបឹងកេងកង
រាជធានីភ្នំពេញ
ទូរសព្ទលេខ៖ (៨៥៥) ៧៧ ២៥ ២១ ២១ / (៨៥៥) ២៣ ៦៥៥ ៥៣៩៥
សារអេឡិចត្រូនិក៖ info@tuolsleng.gv.kh
គេហទំព័រ៖ www.tuolsleng.gov.kh

រក្សាសិទ្ធគ្រប់យ៉ាងដោយ៖ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

ISBN: 978-9924-574-01-9
បោះពុម្ពនៅកម្ពុជា ឆ្នាំ២០២០

# មាតិកា

**ទំព័រ**


| | |
|---|---|
| ១ | **អារម្ភកថា** |
| ៣ | **សេចក្ដីផ្ដើម** |
| ៧ | **១. ប្រវត្តិអមលាំង** |
| ១១ | **២. ការបង្កើតមន្ទីរ១៣(ម-១៣)** |
| ១៣ | ២.១ អំពីភូមិភាគពិសេស និងការបង្កើតមន្ទីរ១៣ |
| ១៤ | ២.២ ការផ្លាស់ប្ដូរទីតាំង |
| ១៧ | **៣. រចនាសម្ពន្ធ** |
| ១៩ | ៣.១ តួនាទី ឌុច |
| ២១ | ៣.២ កងកាពារ |
| ២៣ | **៤. អ្នកជាប់ឃុំ** |
| ២៦ | ៤.១ មូលហេតុនៃការចាប់ខ្លួន |
| ២៧ | ៤.២ ការងារអ្នកជាប់ឃុំ |
| | ៤.៣ ចំនួនអ្នកស្លាប់ |
| | ៤.៤ ទារុណកម្ម និងសួរចម្លើយ |
| ២៩ | **៥. ស្ថានភាពរស់នៅ** |
| ៣២ | ៥.១ របបអាហារ |
| | ៥.២ សេដ្ឋកិច្ច |
| | ៥.៣ ទឹកជំនន់ |
| ៣៣ | **៦.សេចក្ដីសន្និដ្ឋាន** |
| ៣៧ | **ចំណាប់អារម្មណ៍** |
| ៤១ | **សេចក្ដីថ្លែងអំណរគុណ** |
| ៤៣ | **កំណត់ចំណាំ** |

# អារម្ភកថា



ការសិក្សាប្រវត្តិសាស្ត្រ ជាកត្តាចាំបាច់សម្រាប់យុវជនជំនាន់ក្រោយដើម្បីឲ្យបានស្វែងយល់ពីព្រឹត្តិការណ៍នាអតីតកាល និងបញ្ចៀសកុំឲ្យកើតឡើងវិញនូវប្រវត្តិសាស្ត្រសោកនាដកម្ម។ ដើម្បីសិក្សាពីប្រវត្តិសាស្ត្រ ទាមទារឲ្យមានការស្រាវជ្រាវ ការអានសៀវភៅ ការទស្សនាវិដេអូឯកសារ និងទស្សនាសារមន្ទីរ។ល។

ជាក់ស្តែងសារមន្ទីរទួលស្លែង ដែលជាអតីតមន្ទីរឃុំឃាំងស-២១ ក្នុងសម័យខ្មែរក្រហម ត្រូវរដ្ឋាភិបាលប្រែក្លាយឲ្យទៅជាសារមន្ទីរចាប់ពីឆ្នាំ១៩៧៩។ គោលបំណងចម្បងនៃការរៀបចំសារមន្ទីរទួលស្លែង គឺដើម្បីផ្សព្វផ្សាយពីសោកនាដកម្ម និង ចងចាំដល់ជនរងគ្រោះក្នុងសម័យខ្មែរក្រហម។ ដើម្បីសម្រេចគោលបំណងខាងលើសារមន្ទីរបានខិតខំអភិរក្ស ថែរក្សាវត្ថុតាងនានាដែលនៅសេសសល់ក្នុងបរិវេណអតីតមន្ទីរស-២១ និងផ្សព្វផ្សាយព្រឹត្តិការណ៍សោកនាដកម្ម។ ក្រៅពីនេះ សារមន្ទីរក៏មានរៀបចំជាវគ្គបណ្តុះបណ្តាលស្រាវជ្រាវអំពីប្រវត្តិសាស្ត្រខ្មែរក្រហមដើម្បីជម្រុញនិងលើកទឹកចិត្តសិស្សនិស្សិតឲ្យចាប់អារម្មណ៍លើការស្រាវជ្រាវពីប្រវត្តិសាស្ត្រ និង ដើម្បីផ្សព្វផ្សាយឲ្យបានទូលាយពីប្រធានបទផ្សេងៗទាក់ទងនឹងសម័យខ្មែរក្រហម។

តួយ៉ាងគម្រោងសិក្សាស្រាវជ្រាវអំពី "ម-១៣៖ មន្ទីរសន្តិសុខខ្មែរក្រហមក្នុងសម័យសង្គ្រាម(១៩៧០-១៩៧៥)" គឺជាផ្នែកមួយនៃការបណ្តុះបណ្តាលស្រាវជ្រាវលើប្រធានបទទាក់ទងនឹងសម័យខ្មែរក្រហម និងរួមចំណែកចងក្រងឯកសារប្រវត្តិសាស្ត្រ។ ទោះបីជាប្រធានបទនេះ ធ្លាប់បានលើកឡើងក្នុងសាលាក្តីខ្មែរក្រហម អំឡុងពេលដំណើរការសំណុំរឿង ០០១ និង ធ្លាប់បោះពុម្ពផ្សាយក្នុងអត្ថបទទស្សនាវដ្តីក៏ដោយ ការសិក្សានេះនៅមិនទាន់បង្ហាញរឿងរ៉ាវលម្អិតនៅឡើយ ហើយទាមទារឲ្យមានការសិក្សាបន្ថែម។ ម្យ៉ាងទៀតកិច្ចការស្រាវជ្រាវនេះ ក៏ជាផ្នែកមួយក្នុងការចងក្រងព័ត៌មានស្តីពីមន្ទីរ១៣ សម្រាប់ការស្នើសុំចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ដ្បិតមន្ទីរ១៣ ស្ថិតក្នុងបេក្ខភាពដែលត្រូវដាក់ជារួមក្នុងបញ្ជីបេតិកភណ្ឌពិភពលោកជាមួយនឹងសារមន្ទីរទួលស្លែង និងមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក។ មួយវិញទៀត ការសិក្សានេះក៏អាចរួមចំណែកជាមគ្គុទេសក៍សម្រាប់យុវជនជំនាន់ក្រោយដើម្បីបន្តធ្វើការសិក្សាចងក្រងទីតាំងសោកនាដកម្មនានានៅក្នុងប្រទេសកម្ពុជា។ របាយការណ៍ស្រាវជ្រាវនេះ កើតឡើងដោយកិច្ចខិតខំប្រឹងប្រែងរបស់ប្អូនៗ និស្សិតមកពីមហាវិទ្យាល័យបុរាណវិទ្យានៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ព្រមទាំងបុគ្គលិកផ្នែកស្រាវជ្រាវរបស់សារមន្ទីរដែលទទួលបន្ទុកសម្របសម្រួលកិច្ចការស្រាវជ្រាវ។ ខ្ញុំ ជឿជាក់ថារបាយការណ៍នេះ នឹងមានភាពខ្វះចន្លោះដោយប្រការណាមួយជាក់ជាពុំខាន ដ្បិតលទ្ធភាពនិងពេលវេលាមានកម្រិត។ ម្យ៉ាងទៀតការសិក្សានេះ គ្រាន់តែជាលទ្ធផលបឋមប៉ុណ្ណោះ។

ខ្ញុំសូមអរគុណដល់លោក កែវ ដួង គ្រូឧទ្ទេសផ្នែកប្រវត្តិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញដែលបានជួយផ្តល់យោបល់ផ្នែកប្រវត្តិសាស្ត្រដល់និស្សិតស្រាវជ្រាវ មន្ត្រីនិងបុគ្គលិកផ្នែកអប់រំផ្សព្វផ្សាយ និង ផ្នែកស្រាវជ្រាវដែលបានជួយសម្របសម្រួលកិច្ចការស្រាវជ្រាវឲ្យដំណើរការដោយរលូន។ ជាពិសេស មូលនិធិខុនរ៉ាដប្រចាំប្រទេសកម្ពុជា ដែលបានឧបត្ថម្ភផ្នែកហិរញ្ញវត្ថុដល់ដំណើរការស្រាវជ្រាវនេះ។

ដោយការស្រលាញ់និងរាប់អានអំពីខ្ញុំ!

**លោក ហង្ស និស្ស័យ**

**ប្រធានការិយាល័យសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង**



ទោះបីជារបបប្រល័យពូជសាសន៍ខ្មែរក្រហម កន្លងផុតទៅជាងបួនទសវត្សរ៍ហើយក៏ដោយ ក៏ការចងចាំពីព្រឹត្តិការណ៍ដ៏ឃោរឃៅនៃរបបនេះនៅតែជិតជាប់ជាមួយប្រជាជនកម្ពុជា។ របបនេះ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដ៏ធ្ងន់ធ្ងរបំផុតមួយក្នុងដំណាក់កាលប្រវត្តិសាស្ត្រទំនើប។ ក្នុងរយៈពេលប្រមាណជាង ២០ឆ្នាំចុងក្រោយនេះ មូលនិធិខុនរ៉ាដប្រចាំប្រទេសកម្ពុជា បានប្រតិបត្តិបេសកកម្មរបស់ខ្លួនដោយសហការជាមួយដៃគូរក្នុងស្រុកជាច្រើនបំណងរួមចំណែកកសាងកម្ពុជាឲ្យបានប្រសើរឡើងវិញ។ ការងារចម្បងមួយរបស់យើង គឺការកសាងសន្តិភាពសម្រាប់កម្ពុជា។ តាំងពីឆ្នាំ២០១៧មក មូលនិធិខុនរ៉ាដបានសហការ និងគាំទ្រសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង តាមរយៈគម្រោងមួយចំនួនក្នុងដំណើរការសិក្សាស្រាវជ្រាវពីប្រវត្តិសាស្ត្រខ្មែរក្រហម។

មន្ទីរ១៣ ដែលមានទីតាំងនៅក្នុងខេត្តកំពង់ស្ពឺ (បច្ចុប្បន្នស្ថិតក្នុងព្រំប្រទល់រដ្ឋបាលនៃខេត្តកំពង់ឆ្នាំង) ត្រូវខ្មែរក្រហមប្រើប្រាស់ជាគុកដាក់អ្នកជាប់ឃុំដ៏សំខាន់មួយក្នុងដំណាក់កាលដំបូង មុនឡើងកាន់អំណាចនៅឆ្នាំ១៩៧៥។ ខ្មែរក្រហម ប្រើប្រាស់ទីតាំងនេះ ដើម្បីឃុំឃាំង ធ្វើទារុណកម្ម និងសម្លាប់ពលរដ្ឋខ្មែរស្លូតត្រង់នៅចន្លោះឆ្នាំ១៩៧១-១៩៧៥។ ការយល់ដឹងពីអ្វីដែលបានកើតឡើងនៅក្នុងអតីតគុក ម-១៣នេះ គឺជាចំណុចដ៏សំខាន់ក្នុងការសិក្សាស្វែងយល់ពីដំណើរវិវត្តនៃមនោគមវិជ្ជារបស់ខ្មែរក្រហម ដំណើរប្រព្រឹត្តទូទៅនៃការឃុំខ្លួន និងធ្វើទារុណកម្មអ្នកជាប់ឃុំតាំងតែពីមុនពេលរបបនេះឡើងកាន់កាប់អំណាចក្នុងខែមេសា ឆ្នាំ១៩៧៥។ ការសិក្សាស្រាវជ្រាវក្រោយៗមកទៀតស្តីពីអតីតគុក ម-១៣ ក៏ត្រូវធ្វើឡើង ប៉ុន្តែសំណេរស៊ីជម្រៅទាក់ទងនឹងមុខងារ និងប្រតិបត្តិការនៃអតីតគុកនេះនៅមានកម្រិតនៅឡើយ។

ដូចនេះសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងបានចាប់ផ្តើម និងសម្រេចបានការសិក្សាស្រាវជ្រាវស៊ីជម្រៅមួយស្តីពីព័ត៌មានដែលពុំត្រូវបានលាតត្រដាងពីមុនមក ទាក់ទងទៅនឹងអតីតគុក ម-១៣ នេះ ដោយរាប់បញ្ចូលទាំងការសិក្សាទៅលើរចនាសម្ព័ន្ធ អ្នកជាប់ឃុំ និងលក្ខខណ្ឌនៃការរស់នៅក្នុងអតីតគុកនោះ។ លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះនឹងផ្តល់ឲ្យយើងនូវការយល់ដឹងដ៏សំខាន់មួយទាក់ទងទៅនឹងដំណើរការដំបូងនៃមនោគមវិជ្ជាអមនុស្សធម៌របស់ខ្មែរក្រហម។ ការសិក្សាស្រាវជ្រាវ បានប្រព្រឹត្តិទៅតាមលំនាំស្តង់ដារនៃវិស័យសិក្សាធិការនិងអាចក្លាយជាមូលដ្ឋានគ្រឹះដ៏សំខាន់មួយសម្រាប់ការសិក្សាស្រាវជ្រាវស្តីពីប្រវត្តិសាស្ត្រកម្ពុជានេះ។

យើងជឿជាក់ថា លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះនឹងចូលរួមចំណែកជាផ្នែកមួយសម្រាប់កម្ពុជាក្នុងការប៉ះប៉ូវរបួសស្នាមដែលបានបន្សល់ទុកពីសោកនាដកម្មនៃអំពើប្រល័យពូជសាសន៍ និងបញ្ចៀសនូវវិនាសកម្មនៃប្រវត្តិសាស្ត្រប្រចំដែល រួមទាំងការកសាងអនាគតមួយដ៏ល្អប្រសើរ។

**បណ្ឌិត ដាញ៉ែល ស្មូតយើង**
**តំណាង ប្រចាំប្រទេសកម្ពុជា**
Konrad-Adenauer-Stiftung

# សេចក្តីផ្តើម

ការសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហម ជាផ្នែកសំខាន់នៃការអប់រំនិងបញ្ចៀសមិនឲ្យមានអំពើហិង្សាកើតឡើងម្តងទៀតនាពេលអនាគត។ ទិដ្ឋភាពហិង្សានៃរបបនេះរំលេចតាមរយៈបទពិសោធន៍នៃការរស់នៅទុរភិក្ស ការជម្លៀស និងការធ្វើទារុណកម្ម-ល-។ បណ្តាញមន្ទីរសន្តិសុខរបស់ខ្មែរក្រហមដែលមានចំនួនប្រមាណ១៩៦ទីតាំងគិតត្រឹមឆ្នាំ២០០៦[1] ជាភស្តុតាងសំខាន់បង្ហាញពីភាពឃោរឃៅព្រៃផ្សៃទាំងអស់នេះដែលបានដាក់អាទិភាពលើការចាប់ខ្លួន ឃុំឃាំង ធ្វើទារុណកម្ម និងសម្លាប់។ ទោះជាយ៉ាងណាក្តី មិនទាន់មានការសិក្សាលម្អិតនិងធ្វើបច្ចុប្បន្នភាពពីទីតាំងគុកទាំងនោះទេរហូតមកដល់បច្ចុប្បន្ន។ ជាក់ស្តែងទីតាំងមួយចំនួនកំពុងឈានទៅរកការបាត់បង់ភស្តុតាង ដោយសារការវាតដីធ្លីធ្វើកសិកម្ម។

ក្នុងចំណោមទីតាំងដែលប្រឈមនឹងការបាត់បង់នេះ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានសង្គ្រោះនិងអភិរក្សទីតាំងអតីតមន្ទីរ១៣ (ម-១៣) នាអំឡុងឆ្នាំ២០១៩។ មន្ទីរ១៣ មានប្រវត្តិទាក់ទងនឹងមន្ទីរស-២១ ឬគុកទួលស្លែង ដ្បិត កាំង ហ្គេកអ៊ាវ ហៅ ឌុច បានគ្រប់គ្រង ម-១៣ ពីឆ្នាំ១៩៧១ រហូតខែមេសា ១៩៧៥ ទើបផ្លាស់ទៅគ្រប់គ្រងមន្ទីរស-២១ ដោយនាំយកមកជាមួយនូវបុគ្គលិក និងវិធីសាស្ត្រនៃការគ្រប់គ្រង ការធ្វើទារុណកម្ម និងការសួរចម្លើយលើជនរងគ្រោះទៅអនុវត្តនៅមន្ទីរស-២១។ ដោយមើលឃើញតម្លៃជាប្រវត្តិសាស្ត្រសម្រាប់មនុស្សជាតិបែបនេះ ទើបអង្គការយូណេស្កូទទួលស្គាល់ទីតាំងទាំងពីរនេះ រួមទាំងមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក(អតីតវាលពិឃាតដែលខ្មែរក្រហមប្រើសម្លាប់ភាគច្រើនជាជនរងគ្រោះពីមន្ទីរស-២១) ទៅក្នុងបញ្ជីបណ្តោះអាសន្ននៃបេតិកភណ្ឌពិភពលោកកាលពីខែឧសភា ឆ្នាំ២០២០[2]។

ខុសពីទួលស្លែងដែលមានភស្តុតាងដូចជាសំណង់អគារ ឯកសារ សមុច្ច័យ និងសក្ខីកម្ម ម-១៣ មិនមានភស្តុតាងរចនាសម្ពន្ធសំណង់សេសសល់នោះទេ។ ម-១៣ បច្ចុប្បន្នសល់ត្រឹមតែស្លាកស្នាមរណ្តៅឃុំឃាំងនៅប្របមាត់ស្ទឹង គ្មានភស្តុតាងឯកសារសំណេរ ហើយមានតែអតីតបុគ្គលិក២នាក់ និងជនរងគ្រោះម្នាក់គត់ ដែលអាចទំនាក់ទំនងដើម្បីសម្ភាសពីព័ត៌មាននៅម-១៣។ ប្រហែលដោយសារបញ្ហានេះ ទើបកន្លងមកមិនមានការស្រាវជ្រាវពីទីតាំង ម-១៣ ស៊ីជម្រៅនោះទេ។

ស្របពេលជាមួយគ្នានេះ ការងាររៀបចំបែបបទស្នើបញ្ចូលទីតាំងអតីត ម-១៣ សារមន្ទីរទួលស្លែង និងមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ចាំបាច់ឲ្យមានការរៀបចំឯកសារប្រវត្តិសាស្ត្រនិងគតិយុត្តមួយចំនួន។ ដោយមើលឃើញពីសារសំខាន់និងភាពចាំបាច់ក្នុងការស្រាវជ្រាវប្រវត្តិសាស្ត្រទីតាំងនេះ សារមន្ទីរទួលស្លែងក្រោមការគាំទ្រពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងការឧបត្ថម្ភពីមូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែ ប្រចាំប្រទេសកម្ពុជា (Konrad-Adenauer-Stiftung Cambodia) បានរៀបចំគម្រោងស្រាវជ្រាវ និងចងក្រងឯកសារ ស្តីពីមន្ទីរ១៣ នេះឡើង។

គម្រោងស្រាវជ្រាវនេះ អនុវត្តចាប់ពីខែកញ្ញា ដល់វិច្ឆិកា ឆ្នាំ២០២០ ដោយបានជ្រើសរើសនិស្សិតជំនាញប្រវត្តិវិទ្យា-បុរាណវិទ្យា ចំនួន៦នាក់ ដើម្បីបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រស្រាវជ្រាវ និងការប្រើប្រាស់បច្ចេកវិទ្យាកំណត់ទីតាំងភូមិសាស្ត្រចំនួន ៥លើក ដោយអ្នកជំនាញប្រវត្តិសាស្ត្រ និងបុរាណវិទ្យា។ ក្រោយឆ្លងកាត់វគ្គបណ្តុះបណ្តាល ក្រុមនិស្សិត បានសិក្សាលើឯកសារបោះពុម្ព និងបទសម្ភាសផ្សេងៗដែលសាលាក្តីខ្មែរក្រហម និងមជ្ឈមណ្ឌលឯកសារកម្ពុជាបានសិក្សាកន្លងមក។ បន្ទាប់មកក្រុមនិស្សិតបានចុះសិក្សាស្រាវជ្រាវចំនួន២លើកនៅទីតាំងអមលាំងនិងតំបន់ជុំវិញ ដោយបានសម្ភាសអ្នកពាក់ព័ន្ធចំនួន ១៦នាក់ (ស្រី៦នាក់) និងសិក្សាលម្អិតលើទីតាំងប្រវត្តិសាស្ត្រពាក់ព័ន្ធជាច្រើន។ ក្នុងចំណោមបទសម្ភាសទាំងនោះ ក្រុមស្រាវជ្រាវបានសម្ភាសអតីតជនរងគ្រោះផ្ទាល់ម្នាក់ អតីតបុគ្គលិក២នាក់ ក្រៅពីនេះសុទ្ធសឹងជាអ្នកធ្លាប់ដឹងពីទីតាំងម-១៣ ឬអ្នកភូមិនៅជុំវិញម-១៣ ចំនួន១៣នាក់។ បន្ទាប់ពីប្រមូលទិន្នន័យទាំងអស់នេះ ក្រុមស្រាវជ្រាវបានវិភាគ និងសរសេរអត្ថបទស្រាវជ្រាវ ដោយមានការឲ្យយោបល់ និងកែតម្រូវពីសារមន្ទីរទួលស្លែង។

# ๑

# ប្រវត្តិអមលាំង

អមលាំងជាឃុំធំមួយ ស្ថិតនៅក្នុងស្រុកថ្ពង ខេត្តកំពង់ស្ពឺ និងមានចម្ងាយ៩០គ.ម ភាគពាយព្យនៃរាជធានីភ្នំពេញ។ នៅចុងទសវត្សរ៍ឆ្នាំ១៩៦០ អមលាំង ជាទីតាំងមូលដ្ឋានសំខាន់មួយរបស់ចលនាខ្មែរក្រហម ដ្បិតតំបន់នេះហ៊ុំព័ទ្ធដោយជួរភ្នំឱរ៉ាល់ និងព្រៃក្រាស់ដែលអំណោយផលដល់ចលនាកុម្មុយនីស្ត[៣]។ ប្រសិនបើពិនិត្យមើលលើទីតាំងភូមិសាស្ត្រ តំបន់អមលាំងស្ថិតនៅចំណុចកណ្តាលរវាងខេត្តកោះកុង ពោធិ៍សាត់ បាត់ដំបង កំពង់ឆ្នាំង ភ្នំពេញ តាកែវ និងកំពង់សោម ដែលសុទ្ធសឹងជាទីតាំងយុទ្ធសាស្ត្រតស៊ូរបស់ខ្មែរក្រហមតាំងពីអំឡុងទសវត្សរ៍១៩៦០។ កត្តានេះ ទើបខ្មែរក្រហមជ្រើសយកទីតាំងអមលាំងជាមូលដ្ឋានតស៊ូមួយនៅក្នុងខេត្តកំពង់ស្ពឺ។ នាដំណាក់កាលដំបូង ខ្មែរក្រហមចូលមកក្នុងតំបន់នេះ ដោយស្នាក់នៅតាមតំបន់ព្រៃក្រាស់ៗក្បែរភូមិ ដើម្បីលាក់ខ្លួនពីការវាយប្រហាររបស់រដ្ឋាភិបាលដែលឈរជើងនៅតាមទីប្រជុំជន[៤]។

នៅឆ្នាំ១៩៧០ លន់ នល់ បានដឹកនាំរដ្ឋប្រហារយោធាដើម្បីទម្លាក់សម្តេចសីហនុ ពីព្រះប្រមុខរដ្ឋ និងបង្កើតរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ដែលមាននិន្នាការប្រឆាំងនឹងចលនាកុម្មុយនីស្តក្នុងប្រទេសកម្ពុជា។ ទោះជាយ៉ាងនេះក្តី រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ មិនអាចគ្រប់គ្រងតំបន់អមលាំងបាននោះទេ ដ្បិតកងទ័ពសាធារណរដ្ឋខ្មែរមានលទ្ធភាពឈរជើងត្រឹមតំបន់ដំណាក់ស្មាច់ ដែលចម្ងាយប្រហែលជាង១០គីឡូម៉ែត្រនៅភាគនិរតីឧដុង្គ ក្បែរព្រំប្រទល់ស្រុកឧដុង្គនិងស្រុងថ្ពងសព្វថ្ងៃ[៥]។

នៅក្នុងការតស៊ូប្រឆាំងនឹងរបបលន់ នល់ ខ្មែរក្រហមបានឃោសនាកៀងគរប្រជាជនក្នុងមូលដ្ឋានឲ្យចូលរួមជាមួយនឹងចលនារបស់ខ្លួនដោយប្រើប្រាស់ប្រជាប្រិយភាពសម្តេចសីហនុ ដ្បិតប្រជារាស្ត្រនៅតាមទីជនបទនៅតែគាំទ្រនិងគោរពស្រលាញ់ព្រះអង្គ[៦]។ បន្ថែមពីនេះ ខ្មែរក្រហមបានប្រើប្រាស់រូបភាពនៃសិល្បៈឃោសនា និងការប្រជុំបំពាក់បំប៉នមនោគមន៍វិជ្ជាទៅលើប្រជាជនមូលដ្ឋាន។ មិនខុសពីតំបន់ផ្សេងៗក្នុងប្រទេសកម្ពុជា ឃុំអមលាំង រងគ្រោះពីការទម្លាក់គ្រាប់បែកពីសំណាក់សហរដ្ឋអាមេរិកនិងកងទ័ពលន់ នល់ ដែលធ្វើឲ្យខូចខាតផ្ទះសម្បែង និងទ្រព្យសម្បត្តិប្រជាជន។ តាមរយៈវិនាសកម្មនៃការទម្លាក់គ្រាប់បែកនេះ ធ្វើឲ្យប្រជាជនរឹតតែមានគំនិតចូលរួមជាមួយខ្មែរក្រហមក្នុងការវាយប្រឆាំងនឹងរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ[៧]។

នៅឆ្នាំ១៩៧១ ទឹកដីអមលាំងបានក្លាយជាតំបន់ពិសេសមួយរបស់បក្សកុម្មុយនីស្តកម្ពុជាដែលប៉ុល ពត បានសម្រេចចិត្តបើកការប្រជុំដើម្បីបង្កើតតំបន់ពិសេស[៨]នៅដំណាច់ឆ្នាំ១៩៧២ ខ្មែរក្រហមបានចាប់ផ្តើមធ្វើប្រតិបត្តិការដោយឯករាជ្យរៀងៗខ្លួន។ នៅពេលជាមួយគ្នានោះ ទឹកដីកម្ពុជាមួយភាគធំបានស្ថិតក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម[៩]។ ដូច្នេះ ឃុំអមលាំងស្ទើរទាំងស្រុងបានក្លាយជាតំបន់រំដោះរបស់ខ្មែរក្រហមមុនការឡើងកាន់អំណាចក្នុងឆ្នាំ១៩៧៥។




រូបភាពផែនទីផ្ទៃដីឃុំអមលាំង មើលក្នុងកម្មវិធី Google Maps

# ໒

# ការបង្កើតមន្ទីរ១៣ (ម-១៣)

## ២.១ អំពីភូមិភាគពិសេស និងការបង្កើតមន្ទីរ១៣

អំឡុងពេលសង្គ្រាមប្រឆាំងលន់ នល់ អង្គការចាត់តាំងខ្មែរក្រហមបានបង្កើតភូមិភាគពិសេសនៅឆ្នាំ១៩៧១[១០]។ ឌុច បានសន្និដ្ឋានថា អ្នកដែលសម្រេចបង្កើតភូមិភាគពិសេសនោះគឺ ប៉ុល ពត ព្រោះឃើញ តាម៉ុក និង វន វ៉េត ទៅប្រជុំជាមួយគ្នា។ តាម៉ុក ជាលេខាភូមិភាគនិរតី ហើយ វន វ៉េត ទទួលការតែងតាំងជាលេខាភូមិភាគពិសេស។ ភូមិភាគពិសេសនោះមានតំបន់ពីរ គឺតំបន់១៥ (ខាងជើងផ្លូវជាតិលេខ៤ និងខាងជើងក្រុងភ្នំពេញ) និង តំបន់២៥ (ខាងត្បូងភ្នំពេញ)។ តំបន់១៥ មាន៤ស្រុក រួមមាន អង្គស្នួល ដង្កោ កណ្ដាលស្ទឹង និងពញាឮ។ តំបន់២៥មាន៤ស្រុក គឺស្អាង កោះធំ លើកដែក កៀនស្វាយ[១១]។

ភូមិភាគពិសេសនៅចន្លោះភូមិភាគនិរតី បូព៌ា និងបស្ចិម ដែលលាតសន្ធឹងលើក្រុងភ្នំពេញដែរ។ នៅក្នុងតំបន់ទាំងពីរនៃភូមិភាគពិសេសមានមន្ទីរសន្តិសុខរៀងៗខ្លួន។ យោងតាមប្រតិចារឹករបស់សាលាក្ដីខ្មែរក្រហមបញ្ជាក់ថា៖ “ជាផ្លូវការមន្ទីរនគរបាលរបស់ភូមិភាគពិសេស ប៉ុន្តែមនុស្សដែលចាប់នៅខាងត្បូងភ្នំពេញ និងខាងផ្លូវលេខ៤ ខាងត្បូងផ្លូវភ្នំពេញ គឺរបស់នៅតំបន់២៥ ត្រូវធ្លាក់លើមន្ទីរនគរបាលរបស់មិត្តតេង។ មន្ទីរ-១៣ទទួលភារៈឃុំឃាំង និងសួរចម្លើយ និងកម្ទេចមនុស្សនៅក្នុងតំបន់១៥”[១២]។

ដូចមន្ទីរសន្តិសុខដទៃទៀតដែរ បេសកកម្មបង្កើតម-១៣ គឺដើម្បីការពារទឹកដីរំដោះ ការពារប្រជាជនក្នុងតំបន់រំដោះ ការពារកុំឲ្យខ្មាំងវាយដណ្ដើមដីរំដោះ និងកុំឲ្យទម្លាក់គ្រាប់បែក ឬលើកទ័ពចូលដីរំដោះ។ ខ្មែរក្រហម អនុវត្តបេសកកម្មរបស់ខ្លួនតាមរយៈការស្វែងរកចាប់ខ្មាំង សួរចម្លើយ ធ្វើទារុណកម្ម និងកម្ទេចខ្មាំង នេះបើតាមការលើកឡើងរបស់ឌុច[១៣]។ លោក ប៊ីហ្សូ ដែលជាអតីតអ្នកជាប់ឃុំម្នាក់នៅម-១៣ និងជាអ្នកនិពន្ធស្នាដៃពី ម-១៣ នាពេលក្រោយមក សន្និដ្ឋានថា ម-១៣ បង្កើតឡើងនា ខែកក្កដា ឆ្នាំ១៩៧១ ក្នុងពេលជាមួយនឹងការប្រជុំបង្កើតតំបន់ពិសេសរបស់ ប៉ុល ពត[១៤]។ ឌុច បានទទួលស្គាល់កាលបរិច្ឆេទនេះ ហើយបន្ថែមថា បានកាន់កាប់នៅម-១៣ ដល់ ថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៥[១៥]។

ចំពោះទីតាំងរបស់ម-១៣ មានការលើកឡើងផ្សេងៗគ្នា។ ដើមឡើយមន្ទីរសន្តិសុខ-១៣ មានទីតាំងស្ថិតនៅតំបន់ថ្មយោងក្នុងព្រៃដ៏ជ្រៅមួយដែលមានចម្ងាយប្រមាណជាពីរគីឡូម៉ែត្រពីផ្ទះអ្នកភូមិ។ នៅឆ្នាំ១៩៧២ ឌុច បានផ្លាស់ប្ដូរទីតាំងមន្ទីរទៅទួលស្វាយមាសនៅជម្រាលភ្នំពីស្ស៊ី។ នាពេលនោះការសួរចម្លើយធ្វើទៅក្រោមការទទួលខុសត្រូវរបស់សមមិត្ត ប៉ុន និងក្រោមការដឹកនាំរបស់សមមិត្ត មាស។ បន្ទាប់ពីមានការបះបោរមួយប្រឆាំងនឹងកងការពារ ព្រមទាំងមានអ្នកជាប់ឃុំរត់គេចខ្លួន ឌុច បានផ្លាស់ប្ដូរទីតាំងមកភូមិព្រែក មុននឹងប្ដូរទៅទីតាំងចុងក្រោយនៅត្រពាំងប្រាបដែលស្ថិតនៅក្នុងភូមិថ្មគុប ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ។ ជាពិសេសមន្ទីរសន្តិសុខនេះបានផ្លាស់ប្ដូរឈ្មោះមកជាមន្ទីរសន្តិសុខ-១៣ ឬមន្ទីរ១៣វិញ[១៦]។

ឌុច រួមជាមួយសមាជិកកម្មាភិបាល និងកងការពារមួយចំនួនបានគ្រប់គ្រងមន្ទីរ១៣យ៉ាងតឹងរ៉ឹង។ ក្នុងបរិវេណមន្ទីរ១៣( គុកត្រពាំងប្រាប ) មានផ្ទះយ៉ាងហោចណាស់បួនសម្រាប់ជាកន្លែងស្នាក់នៅរបស់កម្មាភិបាលនិងកងការពារ និងកន្លែងសួរចម្លើយ។ ចំពោះវិសាលភាពម-១៣ប្រហែលអាចលាតសន្ធឹងដល់ភ្នំពេញ ដ្បិត ឌុច និយាយថាធ្លាប់មានមនុស្សបញ្ជូនមនុស្សមកពីទំនប់កប់ស្រូវក្បែរក្រុងភ្នំពេញទៅដាក់គុកនៅម-១៣[១៧]។

មន្ទីរ១៣ គឺជាទីកន្លែងដែល ឌុច បណ្តុះបណ្តាលនិងបង្វឹកបុគ្គលិកក្មេងៗឲ្យធ្វើទារុណកម្មនិងសួរចម្លើយ និង សម្លាប់អ្នកជាប់ឃុំ[១៨]។ ឌុច ក៏បានទទួលស្គាល់ពីឧក្រិដ្ឋកម្មដែលកើតមានអំឡុងពេលខ្លួនគ្រប់គ្រងមន្ទីរសន្តិសុខ១៣ ដោយលើកឡើងថា៖ “មន្ទីរ១៣ ជាយន្តការឧក្រិដ្ឋកម្មសម្លាប់មនុស្សពីថ្ងៃទី២០ កក្កដា ១៩៧១ រហូតដល់ថ្ងៃទី១៧ មេសា ១៩៧៥”[១៩]។

## ២.២ ការផ្លាស់ប្តូរទីតាំង




១. ថ្មគប់ ទីតាំងទីមួយមន្ទីរ១៣
២. ភ្នំពីស្ប៊ូ ទីតាំងទី២ នៃមន្ទីរ១៣
៣. ភូមិព្រែក ទីតាំងទី៣ នៃមន្ទីរ១៣
៤. ត្រពាំងប្រាប ទីតាំងចុងក្រោយនៃមន្ទីរ១៣

មន្ទីរ១៣ បានផ្លាស់ប្តូរទីតាំងនៅជុំវិញតំបន់អមលាំងជាច្រើនដង ប៉ុន្តែចំពោះមូលហេតុមានការលើកឡើងផ្សេងៗគ្នា។ ទីតាំងម-១៣ មាននៅមានថ្មគុប បន្ទាប់មកភ្នំពីស្ប៊ (នៅខាងកើត អន្លង់វែង) បន្ទាប់មកទៀតនៅភូមិព្រែកជ្រៅ (ហៅភូមិព្រែក) និងចុងក្រោយនៅត្រពាំងប្រាប[២០]។

តាមរយៈសក្ខីកម្មខាងលើ យើងអាចបែងចែកទីតាំងតាមដំណាក់កាលនីមួយៗដូចខាងក្រោម៖

**អន្លង់វែង៖** មកដល់សព្វថ្ងៃមិនមានព័ត៌មានច្បាស់លាស់ទេ តែអាចសន្និដ្ឋានរួមថាទីតាំងដំបូងនេះស្ថិតនៅភូមិថ្មគុប ឃុំអមលាំង។ ទីតាំងនៅអន្លង់វែងនេះ ប្រហែលជាប្រើចាប់តាំងពីកកើតរហូតដល់ខែមករា ឬកុម្ភៈ ឆ្នាំ១៩៧២ ប៉ុន្តែដោយសារតែគ្មានពន្លឺព្រះអាទិត្យគ្រប់គ្រាន់ បញ្ហាអនាម័យ ធ្វើឲ្យអ្នកជាប់ឃុំស្លាប់ច្រើន[២១] ខ្វះថ្នាំសង្កូវ និងមានសំណើម ទើបឌុច ផ្លាស់មកតាំងទីនៅតាលាវ(ជើងភ្នំពីស្ស៊)[២២]។

**តាលាវ(ភ្នំពីស្ស៊)៖** យោងតាមសក្ខីកម្មឌុច នេះជាទីតាំងមន្ទីរ១៣ ទី២[២៣]។ តាលាវ ឬទួលស្វាយមាស មានទីតាំងក្បែរជើងភ្នំពីស្ស៊ (សព្វថ្ងៃស្ថិតក្នុងឃុំអមលាំង) និងមានចម្ងាយប្រហែល២០គីឡូម៉ែត្រខាងលិចភូមិថ្មគុបដែលជាទីតាំងដើម។ ទីតាំងភ្នំពីស្ស៊ ជាទីស្នាក់ការសម្ងាត់មួយរបស់ខ្មែរក្រហមរហូតដល់ឆ្នាំ១៩៧៥[២៤]។ ទោះជាយ៉ាងណាក៏ដោយ ខ្មែរក្រហមប្រើទីតាំងនេះជាមន្ទីរឃុំឃាំងចាប់ពីខែមករា ឬខែកុម្ភៈ ឆ្នាំ១៩៧២ ដល់ខែមីនា ឬមេសាឆ្នាំ១៩៧៣ [២៥]។

ការឃុំឃាំងនៅភ្នំពីស្ស៊ ខ្មែរក្រហមធ្វើរោងដែលមានតែដំបូលឥតជញ្ជាំង ហើយដាក់ខ្នោះជើងអ្នកជាប់ឃុំទាំងយប់ទាំងថ្ងៃ។ ជាទូទៅអ្នកជាប់ឃុំនៅភ្នំពីស្ស៊ត្រូវឲ្យធ្វើស្រែនៅពេលថ្ងៃ។ បន្ទាប់ពីដំណើរការមួយរយៈ មានព្រឹត្តិការណ៍អ្នកជាប់ឃុំចំនួន៣០ ឬ៤០នាក់ បះបោរប្រឆាំងជាមួយខ្មែរក្រហម ដែលបង្ខំឲ្យធ្វើស្រែធ្ងន់ធ្ងរនិងឲ្យអាហារមិនគ្រប់គ្រាន់។ ខ្មែរក្រហមសម្រេចប្តូរទៅទីតាំងថ្មីក្រោយប្រមូលអ្នកជាប់ឃុំរួចមកវិញ ស្របនឹងមានការទម្លាក់គ្រាប់បែក[២៦]។

**ភូមិព្រៃក៖** ខែមីនា ឆ្នាំ១៩៧៣ ឌុច បានផ្លាស់ទៅតាំងទីនៅភូមិព្រៃក ឃុំអមលាំង ស្រុកថ្ពង។ នៅភូមិព្រៃកគ្រាន់តែធ្វើរោងសំចតបណ្តោះអាសន្នប៉ុណ្ណោះ ទម្រាំគុកត្រពាំងប្រាបធ្វើហើយ។ ដូចគ្នាដែរ អ្នកជាប់ឃុំភាគច្រើន គឺត្រូវធ្វើស្រែចម្ការ។ ខ្មែរក្រហមនៅទីតាំងនេះ ប្រហែល៣ខែប៉ុណ្ណោះ[២៧]។ ដោយសារការស្នាក់នៅភូមិព្រៃកមានរយៈពេលខ្លីពេក ឌុចបានស្នើសុំទៅសាលាក្តីខ្មែរក្រហមថាមិនគួររាប់បញ្ចូលក្នុងដំណាក់កាលស៊ើបសួរនៃសំណុំរឿង០០១នោះទេ[២៨]។

**ត្រពាំងប្រាប៖** ជាទីតាំងចុងក្រោយនៃមន្ទីរឃុំឃាំងម-១៣ ហើយប្រជាជនបានហៅទីតាំងនេះថាគុកត្រពាំងប្រាប[២៩]។ សព្វថ្ងៃអតីតគុកត្រពាំងប្រាបនេះស្ថិតក្នុងភូមិព្រៃជ្រៅ ឃុំក្បាលទឹក ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។ ដំបូងមន្ទីរនេះ ដាក់អ្នកជាប់ឃុំនៅក្នុងខ្ទមតូច ក្រោយមកបានប្តូរទៅជីករណ្តៅសម្រាប់ឃុំឃាំង[៣០]។ នៅម-១៣ អ្នកយាមយកឬស្សីដែលត្រាំទឹក រួចត្បាញជាប្រដេសដើម្បីធ្វើជារបងព័ទ្ធជុំវិញមន្ទីរឃុំឃាំង។ ក្នុងមួយរណ្តៅអាចឃុំឃាំងមនុស្សចន្លោះពី៥ ទៅ១០នាក់ ដោយដាក់ខ្នោះជើងជាមួយនឹងរនុកដែកមួយ។ អ្នកជាប់ឃុំនៅទីនោះ សម្រាប់មនុស្សស្រីមានភារកិច្ចដាំដំណាំ និងមនុស្សប្រុសជីកប្រឡាយលើកទំនប់ជាដើម។ រីឯក្មេង មានតួនាទីជាកងការពារយាមអ្នកជាប់ឃុំដែលមានខ្សែអង្រឹងចងជាប់ក[៣១]។

អ្នកស្រី ហ៊ិន នៅ ជាអ្នកភូមិជុំវិញតំបន់នោះរំឭកថាប្តីរបស់គាត់ឃើញខ្មែរក្រហមរៀបចំមន្ទីរឃុំឃាំងនេះ ពេលទៅរកត្រីនៅស្ទឹងក្បែរនោះ ហើយគ្រាន់តែឃើញអន្លង់ក៏ត្រឡប់មកវិញទាំងញាក់ញ័រ ដោយខ្លាចខ្មែរក្រហមចាប់[៣២]។

លោក ដួង ណេន បានរំឭកឡើងវិញថា ត្រពាំងប្រាបជាទីតាំងចុងក្រោយរបស់ម-១៣[៣៣]។

ចាប់ពីដើមឆ្នាំ១៩៧៥ មន្ទីរ១៣ ហាក់លែងមានសកម្មភាព ដោយខ្មែរក្រហមផ្តោតការយកចិត្តទុកដាក់លើការរំដោះរដ្ឋធានីភ្នំពេញ។ បន្ទាប់ពីខ្មែរក្រហមទទួលបានជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សុន សេន ដែលជាអគ្គសេនាធិការកងទ័ពខ្មែរក្រហម បានបញ្ជាឲ្យរំសាយមន្ទីរ១៣ ហើយត្រូវផ្លាស់ឧបមកធ្វើការងារនៅភ្នំពេញវិញ។ បុគ្គលិកដែលធ្លាប់ធ្វើការនៅមន្ទីរ១៣ ក៏បានបន្តធ្វើការងារនៅភ្នំពេញដែរ។ ចំណែកឯអ្នកជាប់ឃុំដែលនៅសេសសល់ក្នុងមន្ទីរ១៣ ត្រូវផ្លាស់ទៅមន្ទីរ៩៩ ឬមន្ទីរ៣២ និងមួយចំនួនត្រូវយកទៅកម្ទេចចោល[៣៤]។

ប្រជាជននៅឃុំអមលាំង ស្គាល់ម-១៣ តាមរយៈបទពិសោធន៍ឆ្លងកាត់ដោយផ្ទាល់ ការឃើញ និងការនិយាយតៗគ្នា។ តួយ៉ាងលោក ស្រី ជឿន ស្គាល់ម-១៣ នៅពេលលោកធ្វើជាកងឈ្លប និងបញ្ជូនអ្នកជាប់ឃុំទៅទីនោះ[៣៥]។

# ៣

# រចនាសម្ព័ន្ធ



រូបថតប្លង់ចំពីលើទីតាំងអតីតមន្ទីរ១៣
(ប្រភព៖ សារមន្ទីរទួលស្លែង, ២០១៩)

## ៣.១. តួនាទី ឌុច

រចនាសម្ពន្ធក្នុងមន្ទីរ១៣ បែងចែកជាច្រើនផ្នែក និងមានតួនាទីខុសៗគ្នា។ ប្រធាននគរបាលនៅមន្ទីរ១៣ ធ្លាប់ជាប់គុកនាអំឡុងទសវត្សរ៍ឆ្នាំ១៩៦០ និងជាសមាជិកត្រៀមនៃចលនាខ្មែរក្រហម ប៉ុន្តែក្រោយមកក្លាយជាសមាជិកពេញសិទ្ធិនៃចលនានេះ គឺ កាំង ហ្កេកអ៊ាវ ហៅ ឌុច[៣៦]។ ឌុច ត្រូវតែងតាំងឲ្យធ្វើជាប្រធានសន្តិសុខពិសេសដោយ វ៉ន វ៉េត ដែលជាមេផ្ទាល់។ ការងាររបស់ឌុចនៅមន្ទីរ១៣ ជាអ្នកចាត់ចែងការងាររបស់បក្ស ដោយត្រូវពង្រឹងស្មារតីដែលជាមាគ៌ារបស់បក្សតាមរយៈការប្រជុំទិតៀន និងស្វ័យទិតៀន ឬប្រជុំជីវភាពរៀងរាល់កន្លះខែម្តង[៣៧]។ មួយសប្តាហ៍ម្តង ឌុច កោះហៅសមាជិករបស់ខ្លួនតាមសាខាមួយចំនួនរបស់មន្ទីរសន្តិសុខមកចូលរួមប្រជុំនៅមន្ទីរ១៣។ លើសពីនេះ នៅរៀងរាល់៣សប្តាហ៍ម្តង ឬមួយខែម្តង ឌុច តែងតែចេញទៅប្រជុំនៅក្រៅមន្ទីរ១៣[៣៨]។ អ្នកភូមិឃើញ ឌុច ធ្វើដំណើរទៅប្រជុំដោយជិះម៉ូតូម៉ូប៊ីឡែតកាត់តាមភូមិកុមារមាសជាញឹកញាប់[៣៩]។ ប៉ុន្តែ គ្មាននរណាដឹងថា ឌុច ចេញទៅប្រជុំនៅទីណានោះទេ ហើយរាល់ពេលដែលត្រឡប់មកពីប្រជុំវិញ ឌុច តែងតែមានការងារថ្មីបន្ថែមទៀតដល់កម្មាភិបាលថ្នាក់ក្រោម និងអ្នកជាប់ឃុំ[៤០]។



ក្រៅពីការងារបក្សនិងជាអ្នកគ្រប់គ្រង ឌុច មានភារកិច្ចទទួលខុសត្រូវនិងគ្រប់គ្រងកងការពារ ព្រមទាំងអ្នកជាប់ឃុំនៅមន្ទីរ១៣ ដោយផ្ទាល់។ ប្រសិនបើមានជាប់ឃុំមកពីភូមិភាគពិសេស ឌុច ត្រូវរាយការណ៍ឲ្យ វ៉ន វ៉េត ប៉ុន្តែបើមានអ្នកជាប់ឃុំមកពីភូមិភាគនិរតី ត្រូវរាយការណ៍ទៅ ជូ ជេត ហៅ ស៊ុ ពេលខ្លះជូន ប៉ាល់។ នៅពេលនោះ ឌុច ស្ថិតក្រោមបញ្ជាផ្ទាល់របស់ វ៉ន វ៉េត និងក្រោមបង្គាប់កម្មាភិបាលមួយចំនួនរួមមាន តាម៉ុក ជូ ជេត ជាដើម។ អ្នកមានសិទ្ធិបន្ទាប់គឺ ម៉ម ណៃ ហៅ ចាន់ ជាអនុប្រធាន និងមានភារកិច្ចទទួលខុសត្រូវក្នុងមន្ទីរនៅពេលអវត្តមានឌុច ព្រមទាំងមាននាទីសួរចម្លើយទៅអ្នកជាប់ឃុំដែលមានឋានៈខ្ពស់ៗ។ បន្តមកទៀតមាន ប៉ុន និង ផល ដែលជាអ្នកទទួលខុសត្រូវលើការសួរចម្លើយ និងធ្វើទារុណកម្ម[៤១]។ លើសពីនេះ អ្នកទទួលបន្ទុកកម្ទេច ឬអាចហៅម្យ៉ាងទៀតថាក្រុមសម្លាប់ មានអាយុក្រោម១៨ឆ្នាំ។ មួយក្នុងចំណោមនោះឈ្មោះ មិត្ត មាស ចាប់ផ្តើមធ្វើការនេះនៅអាយុ១៦ឆ្នាំ។ កម្មាភិបាលអស់ទាំងនោះ គឺជាអ្នកដែលបក្សទុកចិត្ត និងអាចសម្រេចឲ្យធ្វើទារុណកម្មលើអ្នកជាប់ឃុំ ចំណែកកងការពារចាំតែទទួលកិច្ចការពីថ្នាក់លើបញ្ជា[៤២]។

ឌុច បានជ្រើសរើសបុគ្គលិកសរុបប្រមាណជា១៧ទៅ២០នាក់ ដោយស្មើក្មេងៗនៅក្នុងមូលដ្ឋានស្រាប់និងយកមកពីភ្នំពេញប្រមាណ១០នាក់។ ក្រៅពីកងការពារក៏មានកុមារផ្សេងទៀត ធ្វើជានារសាដែលអាយុទាបបំផុត១២ឆ្នាំ[៤៣]។ ឌុច បានជ្រើសយកនារសាដោយផ្ទាល់រួមមាន សើ និង ឆេន[៤៤]។

## ៣.២. កងការពារ

កងការពារ មាននាទីការពារអ្នកជាប់ឃុំក្នុងមន្ទីរឃុំឃាំង ដោយត្រូវយាមអ្នកជាប់ឃុំកុំឲ្យលួចរត់ចេញទៅក្រៅ[៤៥]។ មួយទៀតកងការពារ ត្រូវឃ្លាំមើលអ្នកជាប់ឃុំកម្រិតស្រាលដែលត្រូវឲ្យធ្វើការងារនៅពេលថ្ងៃ[៤៦]។ កងការពារអ្នកជាប់ឃុំនៅទីនោះ រៀបចំបានយ៉ាងល្អនិងមានវិន័យតឹងតែង ហើយដឹងច្បាស់នូវអ្វីដែលត្រូវធ្វើដោយមិនចាំបាច់ត្រូវ ឌុច បញ្ជា[៤៧]។ កងការពារ ភាគច្រើនជាកុមារអាយុក្រោម១៥ឆ្នាំរស់នៅក្នុងមូលដ្ឋានតំបន់នោះស្រាប់ ហើយ ឌុច ជាអ្នកជ្រើសរើសដោយផ្ទាល់[៤៨]។ ខ្មែរក្រហមកំណត់ចាត់ទុកអ្នកទាំងនោះជាមនុស្សដែលមិនទាន់មានការបំពុលដោយសង្គម និងគួរឲ្យទុកចិត្តជាងមនុស្សដែលមានអាយុច្រើន។ ក្មេងៗទាំងនោះ ត្រូវបំបែកចេញពីឪពុកម្តាយ និងត្រូវបំពាក់បំប៉ន់ឲ្យជឿលើអង្គការដោយងងឹតងងល់ ហើយត្រូវធ្វើតាមបញ្ជាមិនឲ្យទាស់ បើទោះជាមិនសមហេតុផលក៏ដោយ[៤៩]។ កងការពារមានប្រហែលជាង ១០នាក់ ដែលស្ថិតក្រោមបញ្ជារបស់ឌុចក្នុងនោះរួមមាន ចាន់ វឿន ចាន់ ខន អឹម វន(ហៅឌិន) ណិន។ល។ អ្នកទាំងនោះភាគច្រើន មានអាយុចន្លោះពី៧ ទៅ១៥ឆ្នាំ ហើយមិនសូវមានយុទ្ធសាស្ត្រសម្រាប់ការពារអ្វីឡើយពីមុន[៥០]។

ទោះជាយ៉ាងណាក៏ដោយ កងការពារមួយចំនួនដែលបញ្ជូនមកធ្វើការក្នុងមន្ទីរនេះ មិនបានស្ម័គ្រចិត្តមកធ្វើការ ឬទទួលបានការជ្រើសរើសពី ឌុច ដោយផ្ទាល់នោះទេ។ បើតាមបទសម្ភាសន៍ លោក ចាន់ វឿន ដែលជាអតីតកងការពារក្នុងមន្ទីរ១៣ បានរៀបរាប់ថា មុននឹងចូលធ្វើជាកងការពារមន្ទីរ១៣ នេះ លោកជាទាហានខ្មែរក្រហមដែលវាយនៅក្នុងទឹកដីខេត្តកំពង់ឆ្នាំង។ ក្រោយមក លោករងការវាយប្រហារពីក្រុមទាហានសាធារណរដ្ឋខ្មែរ ហើយរត់មកនៅផ្ទះ។ អំឡុងពេលស្នាក់នៅផ្ទះ ខ្មែរក្រហមបញ្ជូនឲ្យទៅហាត់យុទ្ធសាស្ត្រនៅស្ទឹង១៣[៥១] ទើបបញ្ជូនមកមន្ទីរ១៣ ដោយពុំបានដឹងខ្លួន[៥២]។ ចំណែក ចាន់ ខន វិញ មេភូមិបញ្ជូនទៅមន្ទីរ១៣ ដោយប្រាប់ថាមកធ្វើយោធា ប៉ុន្តែពេលមកដល់មន្ទីរ១៣ បែរជាធ្វើអ្នកយាមទៅវិញ[៥៣]។

កងការពារត្រូវបែងចែកវេនយាមអ្នកជាប់ឃុំ ដោយផ្លាស់ប្តូរវេនគ្នាជាបន្តបន្ទាប់ក្នុងរយៈពេលខ្លីៗ។ អំឡុងពេលយាម កងការពារគ្មានសិទ្ធិទៅអង្គុយក្បែរអ្នកជាប់ឃុំ ឬសម្រាកនៅមួយកន្លែងឡើយ។ ប្រសិនបើមានការធ្វេសប្រហែសឲ្យអ្នកជាប់ឃុំលួចរត់រួច កងការពារនឹងទទួលរងទារុណកម្មដូចអ្នកជាប់ឃុំដែរ។ ចាន់ វឿន បានរៀបរាប់ថា ស្ទើរតែពុំបានសម្រាកពេញមួយយប់ ព្រោះការផ្លាស់ប្តូរពេលវេលាយាមនេះមានរយៈពេលខ្លីពេក។ ចាន់ វឿន បានបណ្តោយឲ្យអ្នកជាប់ឃុំដែលជាមិត្តរបស់ខ្លួនបីនាក់លួចរត់ចេញទៅក្រៅបាន ហើយ ឌុច បានដាក់ទារុណ្ណកម្មដោយផ្ទាល់ជាមួយអ្នកជាប់ឃុំដទៃ[៥៤]។ ក្មេងៗដែលជាកងការពារត្រូវធ្វើទិតៀន ស្វ័យទិតៀន សារភាពអំពីកំហុសរបស់ខ្លួននៅចំពោះសមាជិកក្រុម។ ការធ្វើទារុណកម្ម និងសម្លាប់អ្នកជាប់ឃុំ ក៏ជាកិច្ចការមួយផ្នែកទៀតរបស់កងការពារដែរ ដូចការរៀបរាប់របស់ ហម អ៊ីន បាននិយាយថា ចំពោះអ្នកជាប់ឃុំមួយចំនួនដែលចាប់មកពីទីកន្លែងផ្សេងៗ កងការពាររបស់មន្ទីរ១៣ចាប់ដោយផ្ទាល់ដៃ[៥៥]។

ជាទូទៅគណៈមជ្ឈិមបក្ស ជាអ្នកមានសិទ្ធិក្នុងការសម្រេចសម្លាប់ជនណាម្នាក់ ដូច្នេះក្រៅពីបុគ្គលិកមន្ទីរ១៣ គ្មាននរណាដឹងអំពីវិធីសាស្ត្រនៃការសម្លាប់អ្នកជាប់ឃុំ រូបភាព ឬទីតាំងសម្លាប់មនុស្សច្បាស់នោះទេ[៥៦]។ ប៉ុន្តែតាមរយៈការសម្ភាសន៍ជាមួយប្រជាជនមូលដ្ឋានមួយចំនួន  បានឲ្យដឹងថាទីតាំងសម្លាប់អ្នកជាប់ឃុំភាគច្រើននៅក្បែរមន្ទីរនោះផ្ទាល់[៥៧]។

ក្រៅពី ឌុច កម្មាភិបាល កងការពារនៅមន្ទីរ១៣ ក៏មានអ្នកបម្រើការផ្នែកផ្សេងទៀតដែរ ដូចជាអ្នកដាំស្ល (ប្រពន្ធរបស់ចាន់ជាអ្នកគ្រប់គ្រង) ពេទ្យសម្រាប់ព្យាបាល និងផ្នែកសេដ្ឋកិច្ច។ ចាន់ រឿន ធ្វើជាកងការពារនៅមន្ទីរ១៣ បានប្រហែលមួយឆ្នាំ ហើយក្រោយមកក្លាយជាអ្នកសេដ្ឋកិច្ចដែលមាននាទីជាអ្នកស្វែងរកស្បៀងអាហារសម្រាប់ផ្គត់ផ្គង់ក្នុងមន្ទីរ១៣។ ការស្វែងរកអាហារ ធ្វើឡើងដោយដោះដូរទំនិញរវាងតំបន់រំដោះមួយទៅតំបន់រំដោះមួយទៀត(ភាគច្រើនអ្នកម្ដុំអមលាំងទៅនាំយកមកពីម្ដុំលោក់កងជើង)[៥៨]។

ផ្នែកសុខាភិបាល មានគ្រូពេទ្យសម្រាប់ព្យាបាល ប៉ុន្តែការព្យាបាលពុំត្រឹមត្រូវទៅតាមវិជ្ជាជីវៈនោះទេ។ តាមសម្ដីរបស់លោក តឿង អូន ដែលបានឃើញដោយផ្ទាល់ភ្នែកនៅពេលគ្រូពេទ្យយកឪពុកទៅលាងរបួសដែលមានសភាពដង្កូវក្នុងទឹកត្រពាំងក្បែរនោះ[៥៩]។

សរុបជារួមមក ក្នុងមន្ទីរ១៣ មាន ឌុច ជាប្រធាន អ្នកសួរចម្លើយ អ្នកធ្វើទារុណកម្ម និងជាអ្នកបញ្ជា។ បន្ទាប់មក ចាន់ អនុប្រធាន ទទួលខុសត្រូវគ្រប់គ្រងអ្នកជាប់ឃុំចូល-ចេញ សួរចម្លើយ និង ធ្វើទារុណកម្ម។ ចំពោះ មាស និង ប៉ុន ជាអ្នកសួរចម្លើយ និងជាសមាជិកក្រុមសម្លាប់។ លើសពីនេះក៏មានអ្នកការពារ អ្នកសេដ្ឋកិច្ច អ្នកដាំស្ល និងពេទ្យ ដែលជាផ្នែកជ្រោមជ្រែងក្នុងមន្ទីរ។

# ៤

# អ្នកជាប់ឃុំ

ខ្មែរក្រហម ចាប់បញ្ជូនអ្នកជាប់ឃុំមកមន្ទីរ១៣ ដោយចោទថាជាគិញ។ លោក ហម អ៊ីន អតីតអ្នកកូតទ្រក្នុងក្រុមល្ខោនចល័តរបស់ខ្មែរក្រហម ត្រូវចាប់ចូលមន្ទីរ១៣ បានរៀបរាប់ថា មានយុទ្ធជន៤នាក់ស្ពាយកាំភ្លើងបានមកចាប់ខ្លួន រួមទាំងមនុស្សចំនួន ៦នាក់ទៀត។ នៅពេលទៅដល់មាត់ស្ទឹងក្បែរមន្ទីរ១៣ យុទ្ធជន៤នាក់នោះ បានទាក់ទងតាមវិទ្យុទៅយុទ្ធជនខ្មែរក្រហមខាងក្នុង ៤នាក់ទៀត ដើម្បីមកទទួលនាំខ្លួននិងអ្នកទាំង៦នាក់ទៀតទៅក្នុងមន្ទីរ[៦០]។

នៅមន្ទីរ១៣ បើសិនមានអ្នកជាប់ឃុំណាម្នាក់រត់រួច គឺត្រូវផ្តល់ព័ត៌មានភ្លាមៗទៅផ្នែកទ័ព និងមូលដ្ឋាន ហើយបើចាប់បាន ត្រូវសម្លាប់ចោលតែម្តង មិនចាំបាច់បញ្ជូនត្រឡប់មកមន្ទីរ១៣ វិញទេ[៦១]។ ទោះជាយ៉ាងណា ធ្លាប់មានករណីអ្នកជាប់ឃុំលួចរត់២ដង។ លើកទី១(នៅភ្នំពីស្យ ឬតាលាវ) មានអ្នកជាប់ឃុំម្នាក់ដណ្តើមកាំភ្លើងពីឆ្មាំគុក ហើយបាញ់ទៅលើអ្នកយាមមួយចំនួនឲ្យរងរបួស។ ក្នុងព្រឹត្តិការណ៍នេះ មានអ្នកជាប់ឃុំប្រហែល៣០នាក់ អាចរត់គេចខ្លួន។ ភ្លាមៗនោះ ឌុច បានរាយការណ៍ទៅថ្នាក់លើ (វ៉ន វ៉េត) និងចាប់បានវិញមួយចំនួន។ បន្ទាប់ពីមានការលួចរត់ចេញអស់ម្តង៣០នាក់នោះ គឺចំនួនអ្នកជាប់ឃុំជាមធ្យមដែលនៅក្នុងការឃុំឃាំងមានប្រហែល១០នាក់ មានន័យថាបើមានច្រើនជាងនេះត្រូវតែកម្ទេចទុកឲ្យនៅសល់ត្រឹមតែប៉ុណ្ណឹង។ ឌុច បានលើកឡើងក្នុងសវនការតុលាការខ្មែរក្រហមទាក់ទងនឹងករណីនេះថា "តែសួរហើយ សុំយោបល់ហើយ គេឲ្យកម្ទេច យើងខ្ញុំកម្ទេចហើយ។ ដូច្នេះមិនដែលមានលើសពី១០នាក់ទេ"[៦២]។

អ្នកជាប់ឃុំនៅមន្ទីរ១៣ មានតែរឿងដាក់ខ្នោះ សួរចម្លើយ ធ្វើទារុណកម្ម ចុងបញ្ចប់កម្ទេច មិនមានរឿងដោះលែងទេ[៦៣]។ ទោះបីជាផែនការកំណត់បែបនេះក៏ដោយ មន្ទីរ១៣ នៅតែមានករណីអ្នកជាប់ឃុំមួយចំនួនត្រូវដោះលែងឲ្យរួចពីការឃុំឃាំង។ ជាក់ស្តែង អ្នកអភិរក្សអង្គរជនជាតិបារាំង( ហ្វ្រង់ស្វ័រ ប៊ីហ្សូ) និងជនជាតិខ្មែរ២នាក់ទៀតបានដើរស្រាវជ្រាវ ដោយចូលទៅរកសាស្ត្រានៅវត្តអូរដឹម ហើយត្រូវកងទ័ពភូមិភាគពិសេសចាប់បញ្ជូនទៅឃុំឃាំងនៅម-១៣។ ដំបូង ឌុច មិនហ៊ានសួរទេ ប៉ុន្តែដោយសារថ្នាក់លើបង្ខំឲ្យសួរជាច្រើនខែព្រោះចោទថាជាសេ-អ៊ី-អា( CIA )។ បន្ទាប់ពីឃុំឃាំងមួយរយៈ និងរកមិនឃើញថាជាគិញសេ-អ៊ី-អា ខ្មែរក្រហមសម្រេចដោះលែង ដោយមានរៀបចំពិធីជប់លៀង និងជូនឯកសារឃោសនាមួយចំនួនដល់លោក ហ្វ្រង់ស្វ័រ ប៊ីហ្សូ។ ប៉ុន្តែខ្មែរ២នាក់ដែលមកជាមួយត្រូវឃុំបន្ត[៦៤]។ ទោះជាយ៉ាងណា មុនពេលដោះលែង ហ្វ្រង់ស្វ័រ ប៊ីហ្សូ ខ្មែរក្រហមបង្ខំឲ្យសរសេរប្រវត្តិរូបលម្អិតជាច្រើនលើកច្រើនសារ[៦៥]។ ក្រៅពីនេះ មានអ្នកជាប់ឃុំមួយចំនួនក៏ត្រូវដោះលែងដែរ ជាក់ស្តែងដូចលោក ហម អ៊ីន ដោយសារតែ ឌុច ធ្លាប់រាប់អានជាមួយឪពុករបស់គាត់[៦៦]។

ការចាប់មនុស្សមកមន្ទីរ១៣ ក៏មានករណីចាប់ទាំងគ្រួសារ ( ប្តី ប្រពន្ធ និងកូន ) ជាក់ស្តែង ករណីឪពុកឈ្មោះ ក្រែក ម្តាយឈ្មោះ ម៉ម នៅឃុំយាយអង្គ  និងមួយគ្រួសារទៀត គឺគ្រួសាររបស់មេឃុំចាស់ឈ្មោះ តឿង និងប្រពន្ធ ព្រមទាំងកូន២នាក់ទៀត ( ឪពុក និងកូនច្បងស្លាប់ )។ ក្រៅពីនេះនៅមានកុមារប្រហែលបួនឬដប់នាក់ទៀតដែលត្រូវចាប់មកឃុំឃាំងជាមួយឪពុកម្តាយ និងចុងក្រោយស្លាប់ទាំងអស់។ តាមសាក្សី ហ្វ្រង់ស្វ័រ ប៊ីហ្សូ បានរៀបរាប់ថា លោកបានឃើញកុមារីម្នាក់មកតាមឪពុករបស់នាងដែលត្រូវនាំខ្លួនមកទីនោះ ក្រោយពីឪពុកត្រូវខ្មែរក្រហមនាំចេញទៅ នាងស្នាក់នៅជាមួយអ្នកយាម និងឲ្យចូលរួមប្រជុំតិទៀន[៦៧]។

អតីតអ្នកជាប់ឃុំឃាំងនៅមន្ទីរ១៣ ម្នាក់ បានរៀបរាប់ថា៖ "ខ្មែរក្រហមចាប់ទាំងពូជ(អ្នកជាប់ឃុំ) ចាប់អស់ម៉ងវាអត់ទុកពូជទេ វាស្អប់ណាស់ខ្មាំង វាថាខ្មាំង បាទ យើងធ្វើការចឹងវាថាខ្មាំងហើយ ខ្មាំង គិញ ជំនាន់ហ្នឹង ចាប់សុទ្ធខ្មាំង សុទ្ធគិញហើយ វាស្អប់ណាស់ សម្លាប់ចោលម៉ង។ គ្រាន់តែបែកទៅ ខ្មែរក្រហម វាមកនៅកាន់កាប់ រើសទ័ព នរណាប្រវត្តិរូបអត់ល្អគេអត់យកទេគេថាគិញគេយកប្រវត្តិរូបល្អ អ្នកក្រ អ្នកមានគេថានាយទុន មូលធន អត់យកទេ នរណាជាប់ខ្សែទាហាន វាចាប់ទាំងប្រពន្ធ កូន ហើយឪពុកខ្ញុំ ធ្វើមេស្រុក ចាប់ទាំងអស់ អត់មានសល់ទេមួយសំបុកហ្នឹងទាំងអស់ម៉ង"[៦៨]។

## ៤.១ មូលហេតុនៃការចាប់ខ្លួន

អ្នកជាប់ឃុំនៅមន្ទីរ១៣ ត្រូវខ្មែរក្រហមចាប់បញ្ជូនពីតំបន់មួយចំនួនរួមមាន អមលាំង ថ្ពង ច័ន្ទស្នា ភូមិក្រូច និងយកពីកន្លែងផ្សេងទៀតព្រោះជាតំបន់ពិសេស[៦៩]។ ខ្មែរក្រហម ចាប់ខ្លួនប្រជាជនមកម្តងៗ ចន្លោះពី៨ ទៅ១០នាក់[៧០]។ អ្នកជាប់ឃុំ ភាគច្រើនត្រូវចោទថាជាគិញពីខាងលន់ នល់ អ្នកមានជម្លោះ ក្នុងភូមិនិងទំនាស់ការងាររណសិរ្ស ប្រជាជនដែលបោសសម្អាតនៅតំបន់អមលាំង អ្នកដែលមាន ទំនាស់ផ្ទៃក្នុង ឬចោទថាជាខ្មាំងលាក់កាំភ្លើង[៧១] ព្រមទាំងមានអ្នកបះបោរប្រឆាំងបដិវត្តន៍ អ្នកមាន និង នាយទុន[៧២]។ ឌុច រៀបរាប់ថា មានអ្នកជាប់ឃុំម្នាក់ជាកម្មាភិបាលមកពីហាណូយ និងម្នាក់ជាសមាជិក តំបន់៣៣ នៃភូមិភាគនិរតី ត្រូវជាប់ឃុំឃាំងនៅមន្ទីរ១៣ នេះ។ ទន្ទឹមនឹងនេះ ចាន់ ខន បានបញ្ជាក់ថាអ្នក ជាប់ឃុំចាប់មកពីមូលដ្ឋានភាគច្រើនចោទថាជាជនក្បត់ គិញ ឬខុសសីលធម៌ និងក្បត់វិន័យផ្សេងៗ[៧៣]។ មូលហេតុមួយទៀត គឺក្រោយពេលមានការទម្លាក់គ្រាប់បែកនៅទីតាំងណាមួយ តែងតែមានការចាប់ខ្លួន ប្រជាជនដែលខ្មែរក្រហមសង្ស័យថាជា គិញ រាយការណ៍ពីកន្លែងលាក់ខ្លួនរបស់ពួកគេទៅឲ្យទាហាន លន់ នល់ ទើបបានជាមានការទម្លាក់គ្រាប់បែក[៧៤]។

ដំបូងឡើយអ្នកជាប់ឃុំភាគច្រើនគឺជាទាហាន ឬប្រជាជនដែលប្រឆាំងនឹងមាគ៌ាបក្ស។ ក្រោយមក មន្ទីរនេះ ចាប់អ្នកមកពីចម្ងាយ និងប្រជាជនថ្មី។ ឆ្នាំ១៩៧៣ កម្មាភិបាលដែលត្រឡប់មកពីហាណូយ ប្រហែលជា ១០នាក់ ត្រូវក្រុមឌុចសួរចម្លើយ និងសម្លាប់ដោយកងការពារក្រោមហេតុផលថាយកទៅ រៀនសូត្រ។ ហម អ៊ិន អតីតអ្នកជាប់ឃុំនៅម-១៣ នាខែមិថុនា ឆ្នាំ១៩៧៣ បានឃើញកម្មាភិបាលមកពី ហាណូយដោយផ្ទាល់ភ្នែក។ ទន្ទឹមនឹងនេះ ចាន់ ខន បានរៀបរាប់ថា កម្មាភិបាលខ្មែរក្រហមទាំងនោះមាន ឋានៈធំ ជាប្រធានកងពល គណៈស្រុក ឬប្រធានវរសេនាតូចជាដើម[៥៧]។

## ៤.២ ការងារអ្នកជាប់ឃុំ

នៅម-១៣ បែងចែកអ្នកជាប់ឃុំជាពីរប្រភេទ គឺអ្នកជាប់ឃុំកម្រិតធ្ងន់ និងអ្នកជាប់ឃុំកម្រិតស្រាល។ អ្នកជាប់ឃុំកម្រិតធ្ងន់ត្រូវដាក់នៅក្នុងរណ្ដៅ និងដាក់ខ្នោះជើងទាំងយប់ទាំងថ្ងៃ ហើយមិនអនុញ្ញាតឲ្យមកធ្វើការនៅខាងក្រៅឡើយ។ ចំណែកអ្នកជាប់ឃុំកម្រិតស្រាលមិនមានដាក់ខ្នោះទេ ហើយត្រូវដោះលែងឲ្យទៅធ្វើការនៅខាងក្រៅដូចជា កាប់ដី ដាំបន្លែ[៧៦] លើកទំនប់ ដាំដំឡូង កាប់ឆ្ការព្រៃ និងរានដីធ្វើស្រែ។ អ្នកជាប់ឃុំទាំងអស់ធ្វើការដោយមានកងការពារបណ្ដើរទៅទាំងជាប់ច្រវាក់ ឬចំណង និងតាមឃ្លាំមើលជាប្រចាំ[៧៧]។

តាមសាក្សី គឿង អួន បានឲ្យដឹងថា នៅពេលព្រឹកព្រលឹម អ្នកជាប់ឃុំត្រូវឡើងស្រោចបន្លែ កាប់រណ្ដៅដាំត្រកួន ប៉េងប៉ោះ ត្រប់ ស្ពៃជាដើម។ ម្ដាយលោក គឿង អួន ដែលចាប់ទៅជាមួយគ្រួសារ ត្រូវខ្មែរក្រហមចាត់ឲ្យជាអ្នកដាំស្លនៅកន្លែងចុងភៅ ដោយដាំបាយនឹងខ្ទះឆ្នោត សម្រាប់អ្នកដែលធ្វើការនៅក្នុងគុក[៧៨]។

## ៤.៣ ចំនួនអ្នកស្លាប់

អ្នកស្លាប់នៅម-១៣ យើងមិនអាចដឹងពីចំនួនជាក់លាក់នោះទេ ដ្បិតមិនមានឯកសារសំណេរនៅសេសសល់។ បើយោងតាមទស្សនាវដ្ដីស្វែងរកការពិតបានបញ្ជាក់ថា អ្នកជាប់ឃុំចំនួន២០០ ឬ៣០០នាក់ត្រូវសម្លាប់នៅរណ្ដៅមួយដែលមានចម្ងាយពីមន្ទីរប្រហែល១០០ម៉ែត្រ។ ឌុច តែងតែរាយការណ៍ទៅថ្នាក់លើនៅពេលដែលបានសួរចម្លើយអ្នកជាប់ឃុំបានចំនួន ២ឬ៣នាក់។ ក្រុមអ្នកយកមនុស្សទៅសម្លាប់មានដូចជា មាស ទិត្យ និង ណាន ហើយការសម្លាប់ ត្រូវរក្សាសម្ងាត់មិនឲ្យអ្នកខាងក្រៅអង្គភាពឃើញឡើយ[៧៩]។

អតីតអ្នកជាប់ឃុំ គឿង អួន បានបញ្ជាក់ថា "អ្នកទោសងាប់យកទៅកប់ហ្នឹងគឺឃើញរាល់ថ្ងៃ គ្នាវាអ្នកជញ្ជូនយកទៅចោលគ្មានកប់ទេ ឃើញយកទៅកើតៗមិនដឹងយកទៅដាក់រណ្ដៅ ឬយកទៅស្ទឹងទេ ឃើញដើរហួសស្ទឹង មានឈើសម្រាប់សែង ទាក់កមួយ ទាក់ចង្កេះមួយ មានគ្នាពីរនាក់ដាក់មនុស្សម្ដង២ម្ដង៣ ទៅតាមកម្លាំងដែលសែងរួច"[៨០]។

## ៤.៤ ទារុណកម្ម និងការសួរចម្លើយ

វិធីសាស្ត្រនៃការធ្វើទារុណកម្មនៅម-១៣ គឺមានលំនាំពីការធ្វើទារុណកម្មនៅពន្ធនាគារនៅទសវត្សរ៍១៩៦០ ដោយក្រុម ប៉េ អេស[៨១] ព្រោះឌុចធ្លាប់ជាប់គុកមុនពេលក្លាយជាប្រធានមន្ទីរ១៣។ របៀបដែលចម្លងបានពីនោះគឺវាយនឹងរំពាត់។ ឌុច ធ្លាប់ទទួលការណែនាំពីអង្គការថ្នាក់លើអំពីវិធីសាស្ត្រធ្វើទារុណកម្ម ប៉ុន្តែការណែនាំទាំងនោះឌុចយកមកអនុវត្តតិចតួចប៉ុណ្ណោះ។ វិធីសាស្ត្រភាគច្រើនគឺជាការច្នៃប្រឌិតដោយ ឌុច ផ្ទាល់[៨២]។

ឌុច បានសួរចម្លើយនិងវាយអ្នកជាប់ឃុំយ៉ាងតិច២នាក់ដោយផ្ទាល់។ ក្រៅពីនោះមានអ្នកជាប់ឃុំជាច្រើនទៀតដែលឌុចបញ្ជាឲ្យធ្វើទារុណកម្ម[៨៣]។ នៅក្នុងសវនាការរបស់សាលាក្ដីខ្មែរក្រហម ឌុច បាននិយាយថាការងារនានានៅម-១៣ គឺរក្សាការសម្ងាត់ខ្លាំងណាស់ និងបានបដិសេធសក្ខីកម្មរបស់ ហម អ៊ីន ដែលនិយាយថាខ្លួនបញ្ជាឲ្យសម្លាប់មនុស្ស[៨៤]។

ជាគោលការណ៍នៅក្នុង ម-១៣ គឺ ១)មនុស្សសំខាន់ត្រូវតែសួរចម្លើយដោយ ឌុច ២)ស្រ្តីៗក៏ត្រូវ ឌុច សួរចម្លើយដែរ ព្រោះខ្លាចបុគ្គលិកក្មេងៗប្រព្រឹត្តខុសឆ្គងសីលធម៌ ៣)មនុស្សដែលនឹងអាចដោះលែងបាន[៨៥]។ ការសួរចម្លើយអ្នកជាប់ឃុំនៅម-១៣ មានការផ្តល់យោបល់ពីថ្នាក់លើរបស់ ឌុច តាមភូមិភាគនីមួយៗ[៨៦]។

ការសួរចម្លើយមានលក្ខណៈបង្ខំ ដែលធ្វើឲ្យអ្នកជាប់ឃុំស្ទើរតែទាំងអស់ត្រូវតែឆ្លើយនូវអ្វីដែលអ្នកសួរចង់បាន ឬឆ្លើយថាធ្លាប់ធ្វើនេះធ្វើនោះពីមុនមកបើពុំដូច្នោះទេនឹងទទួលទារុណកម្មរហូតដល់ស្លាប់។ អ្នកជាប់ឃុំមួយចំនួនត្រូវចងភ្ជាប់នឹងបង្គោលក្រាក់ ហើយរ៉តឡើងដើម្បីធ្វើទារុណកម្ម។ បន្ថែមលើនេះ ការសួរចម្លើយ ធ្វើឡើងជារៀងរាល់ថ្ងៃ ហើយអ្នកទទួលខុសត្រូវមាន ឌុច ចាន់ ប៉ុន មាស និង ផល។ អ្នកទាំងនោះមានទីស្នាក់ការសួរចម្លើយរៀងៗខ្លួន។ នៅទីនោះ វ៉ន វ៉េត ជាអ្នកណែនាំ ឌុច អំពីការធ្វើទារុណកម្ម ប៉ុន្តែក្រោយមក ឌុច បានច្នៃប្រឌិតរបៀបធ្វើទារុណកម្ម ដោយយកបទពិសោធន៍ដែលធ្លាប់ជួបក្នុងពន្ធនាគារនាទសវត្សទី៦០[៨៧]។ ឌុច គឺជាអ្នកសួរចម្លើយទៅលើអ្នកជាប់ឃុំដែលមានឋានៈខ្ពស់នៅក្នុងមន្ទីរ១៣។ អ៊ីន ប្រាប់ថា "ឌុច គឺជាមនុស្សកាចសាហាវជាងគេក្នុងការសួរចម្លើយ និងធ្វើទារុណកម្មអ្នកជាប់ឃុំ"។ ចំណែក ប៉ុន និងផល ពុំសូវមាត់ធំដាក់អ្នកជាប់ឃុំទេ[៨៨]។

មួយវិញទៀត ឌុច គឺជាមនុស្សចូលចិត្តលេងសើចជាមួយអ្នកជាប់ឃុំ ប៉ុន្តែបើនឹកឃើញថាចង់សម្លាប់អ្នកជាប់ឃុំណាម្នាក់ គឺបញ្ជាឲ្យកងការពារយកទៅសម្លាប់ចោលភ្លាមៗ[៨៩]។ ឌុច បែងចែកការសួរចម្លើយបីប្រភេទរួមមាន ទី១. សួរស្លូត ឬបបួលអ្នកទោសនិយាយពីនេះពីនោះ(លក្ខណៈនយោបាយ) ទី២. សម្លុតដោយយកដំបង ឬញញួរទៅកំញើញ និងទី៣. និយាយតែពីរបីមាត់វាយតែម្តង។ ក្រៅពីនេះ ឌុច បានធ្វើទារុណកម្មដោយឲ្យអ្នកជាប់ឃុំងូតទឹក ហើយឈរហាលខ្យល់ត្រជាក់។ ប៉ុន្តែក្រោយមក ឌុច ឈប់ធ្វើដោយខ្លាចឈានដល់ការរំលោភផ្លូវភេទលើអ្នកជាប់ឃុំជាស្ត្រី។ ការធ្វើទារុណកម្មបែបផ្សេងទៀតគឺចងផ្តោបនឹងសសរបង្គោលជាច្រើនថ្ងៃ (នេះជាគំនិតរបស់ឌុច) និង ការដុតនឹងភ្លើងចន្លុះ[៩០]។

អតីតអ្នកជាប់ឃុំនៅមន្ទីរ១៣ បានរៀបរាប់ពីសំណួរដែលខ្មែរក្រហមបានសួរខ្លួនថា "វាសួរចម្លើយយើង ហែងខ្មាំង ហែងគិញ ហែងបម្រើខ្មាំងគិញ បម្រើគិញអីចឹងទៅណា ដ៏សួរចម្លើយអញ្ចឹងនិងហ្អែងម៉េចបានបម្រើខ្មាំង ចេះឆ្លើយទៅណា សួរឲ្យឆ្លើយ មិនឆ្លើយក៏ងាប់ ហ្នឹងហើយ ឆ្លើយក៏ងាប់មិនឆ្លើយក៏ងាប់ ហ្នឹងហើយ វា(ខ្មែរក្រហម)សួរថាគិញអញ្ចឹងទៅបើអត់វាវាយដ៏ឆ្លើយ និងឲ្យឆ្លើយ ទៅបើវាចាប់យើងទៅហើយវាថាគិញបានចាប់ វាថាខ្មាំងហ្នឹងហ្អា។ វា សួរចម្លើយនៅក្នុងគុកហ្នឹងណា នៅក្នុងគុកធ្វើរបងព័ទ្ធជុំវិញគ្រាន់វាយកចេញមកសួរចម្លើយ យកចេញពីក្នុងរណ្តៅយកមកលើយប់ឡើងវាដាក់ក្នុងរណ្តៅរណ្តៅវាបួនជ្រុង ជីកបួនជ្រុងក្នុងដីនិងណាស់វាដាក់ខ្នោះដែក អាដែកនិងវាស៊កស៊កទទឹងនេះរត់អត់រួចទេនេះដែកវាមានទំពុកស៊កចេះវាមានបតជើងណារួច បើវាចេះណែនបាត់ហើយចេញអត់រួចទេល្មមម៉ានេះជើងម៉ង"[៩១]។

ប៉ុន្តែបើតាមការលើកឡើងរបស់លោក ហ្វ្រង់ស្វ័រ ប៊ីហ្សូ បានរៀបរាប់ថា លោកមិនដែលទទួលរងការវាយ ឬធ្វើទារុណកម្មនៅម-១៣ ម្តងណាឡើយ[៩២]។



# ស្ថានភាពរស់នៅ

ស្ថានភាពនៃការឃុំឃាំងនៅម-១៣ មានភាពតឹងតែង និងលំបាក ដោយពុំមានថ្នាំសង្កូវ និងអាហារហូបចុកគ្រប់គ្រាន់សម្រាប់អ្នកជាប់ឃុំ ព្រមទាំងកម្មាភិបាល។ ជាពិសេសនៅចុងឆ្នាំ១៩៧៤ អ្នកជាប់ឃុំហូបកន្ទក់ ដំឡូងជ្វា ដំឡូងមី ក្តួចជាដើម ហើយត្រូវជាប់ខ្នោះជើងទាំងយប់ទាំងថ្ងៃ។ រណ្តៅនៅម-១៣មានជម្រៅប្រហែល២ម៉ែត្រ ទទឹងប្រហែល២ម៉ែត្រ បណ្តោយប្រហែលជា៣ម៉ែត្រ និងមានដំបូលគ្របពីលើសម្រាប់អ្នកទោសប្រុស និងស្រី។ ដូច្នេះ លក្ខណៈនៃការឃុំខ្លួនគឺអមនុស្សធម៌បំផុត[៩៣]។

## ៥.១ របបអាហារ

អ្នកជាប់ឃុំនៅមន្ទីរ១៣ ពេលចូលដំបូង ខ្មែរក្រហមមិនឲ្យបាយ ឬបបរហូប៣ថ្ងៃ ព្រោះខ្លាចមានកម្លាំងរត់។ បន្ទាប់មកទើបឲ្យបបររាវមួយវែក ២ដងក្នុងមួយថ្ងៃ ដោយដាក់ក្នុងបំពង់ឫស្សី ឬបំពង់ត្នោតដែលចែកឲ្យម្នាក់មួយ[៩៤] ចំណែកទឹក ផ្តល់ឲ្យមិនគ្រប់គ្រាន់នោះទេ[៩៥]។ បន្ថែមពីនេះ លោក អ៊ុច ស៊ន អតីតជនរងគ្រោះមានជីវិតពីម-១៣ បានលើកឡើងថា ខ្មែរក្រហមឲ្យហូបបបររាល់ថ្ងៃ (ព្រឹកមួយវែក ថ្ងៃល្ងាចមួយវែក)។ ដូចនេះ ការហូបមិនគ្រប់គ្រាន់ទេ ទើបមានអ្នកស្លាប់។ ចំណែកលោក ប្រាង្ស៊ួរ ប៊ីហ្ស បញ្ជាក់ថា អាហារភាគច្រើនជាបាយ ដោយយកអង្ករដែលអ្នកជាប់ឃុំមួយចំនួនបុកនាពេលព្រឹកៗទៅដាំ។ ប្រហែលដោយសារលោក ជាករណីពិសេស ទើបអាចទទួលរបបសម្លដូចអ្នកយាមដែរ[៩៦]។

## ៥.២ សេដ្ឋកិច្ច

សេដ្ឋកិច្ចនៅម-១៣ អាស្រ័យលើទិន្នផលដែលបានពីការដាំដំណាំ ផ្លែឈើ និងការនេសាទ។ ដំណាំភាគច្រើន ដាំនៅក្រៅរបង ក្បែរៗគុក រួមមានត្រកួន ស្ពៃ ឆៃថាវ  និងប៉េងប៉ោះជាដើម ដើម្បីទុកសម្រាប់ការប្រើប្រាស់នៅក្នុងគុក[៩៧]។

## ៥.៣ ទឹកជំនន់

នៅអំឡុងខែតុលា ឆ្នាំ១៩៧៤[៩៨] មានទឹកជំនន់មួយបានកើតឡើងយ៉ាងឆាប់រហ័ស បណ្តាលឲ្យអ្នកជាប់ឃុំដែលមិនអាចរត់ចេញពីរណ្តៅឃុំខ្លួនស្លាប់[៩៩]។ ទាក់ទងនឹងករណីនេះ ចាន់ រឿន បញ្ជាក់ថា លោកបានឃើញផ្ទាល់ភ្នែកនៅពេលមានភ្លៀងធ្លាក់ខ្លាំងបណ្តាលឲ្យមានទឹកជន់ ហើយអ្នកជាប់ឃុំដែលជាប់ខ្នោះក្នុងរណ្តៅត្រូវលង់ទឹកស្លាប់[១០០]។ ទន្ទឹមគ្នានេះដែរលោក តឿង អូន អតីតអ្នកជាប់ឃុំនៅមន្ទីរ១៣បានលើកឡើងថា “នៅពេលទឹកជំនន់ហ្នឹង អត់មានអ្នកណាជួយទេលិចងាប់ខ្លះអត់បានជួយទេ ជួយអត់កើតទេ អត់មាននរណាទៅដោះជើងដោះដៃ ដេកយាមនៅក្រៅមើលនៅក្រៅអត់មានទៅដោះលែងអីទេ វាងាប់ស្រេចចិត្តយើង ប្រកាច់អីក្នុងហ្នឹងចឹងទៅ“[១០១]។ ប៉ុន្តែនៅក្នុងសវនាការ ឌុច បានបដិសេដលើករណីនេះ ដោយបញ្ជាក់ថា គ្មានអ្នកជាប់ឃុំណាម្នាក់ស្លាប់នោះទេ ដ្បិតបានជម្លៀសឡើងលើទួលរួចហើយ[១០២]។

# ๖

# សន្និដ្ឋាន

តាមរយៈការសិក្សាអំពី **មន្ទីរ១៣(ម-១៣)៖ មន្ទីរសន្តិសុខខ្មែរក្រហមក្នុងសម័យសង្គ្រាម (១៩៧០-១៩៧៥)** បង្ហាញឲ្យយើងដឹងថា ចលនាខ្មែរក្រហមបានរៀបចំការដឹកនាំ និងគ្រប់គ្រងច្បាស់លាស់តាំងពីមុនឆ្នាំ១៩៧៥ មកម្ល៉េះ។ ជាក់ស្តែងការរៀបចំបង្កើតឲ្យមានជាមន្ទីរ១៣ ដើម្បីគ្រប់គ្រងនិងឃុំឃាំងមនុស្ស ដោយមានការបញ្ជានិងធ្វើសេចក្តីសម្រេចជាប្រព័ន្ធតាមលំដាប់ពីគណមជ្ឈឹមបក្សទៅកាន់ប្រធានមន្ទីរនេះ។ ចាប់ពីការបង្កើតមន្ទីរ ការជ្រើសរើសប្រធានគ្រប់គ្រង មនុស្សធ្វើការ ការចាប់ខ្លួន និងការសម្រេចកម្ទេចជនជាប់ឃុំ គឺសុទ្ធសឹងតែមានការឆ្លងយោបល់ពីថ្នាក់លើដែលពាក់ព័ន្ធ។ មិនតែប៉ុណ្ណោះ សូម្បីតែវិធីសាស្ត្រនៃការធ្វើទារុណកម្ម ការឃុំឃាំង ក៏ឌុច បញ្ជាក់ដែរថា មានការណែនាំពីថ្នាក់លើផ្ទាល់ គឺ វ៉ន វ៉េត ប៉ុន្តែ ឌុច មិនបានយកមកអនុវត្តទាំងស្រុងនោះទេ។

ចំពោះការបែងចែកការងារបុគ្គលិក ឌុច ខ្លួនឯងផ្ទាល់ជាអ្នកទទួលខុសត្រូវ ហើយនៅពេលចេញទៅប្រជុំឬធ្វើការនៅខាងក្រៅ ចាន់ ដែលជាអនុប្រធានជាអ្នកទទួលខុសត្រូវបន្ទាប់។ បុគ្គលិកនៅមន្ទីរ១៣ ត្រូវបែងចែកជាក្រុមផ្សេងៗគ្នា ដូចជាកងការពារដែលមានភារកិច្ចយាមអ្នកជាប់ឃុំនិងនាំអ្នកជាប់ឃុំទៅធ្វើការនៅខាងក្រៅ ក្រុមសេដ្ឋកិច្ចជាអ្នករកស្បៀងបំពេញតម្រូវការក្នុងមន្ទីរ ក្រុមចុងភៅជាអ្នកចម្អិនអាហារឲ្យបុគ្គលិកនិងអ្នកជាប់ឃុំ និងក្រុមស្លួចម្លើយលើអ្នកជាប់ឃុំ។ បុគ្គលិកតាមផ្នែកនីមួយៗ សុទ្ធតែទទួលបានការអប់រំ ណែនាំពីរបៀបនៃការធ្វើការពី ឌុច ហើយពេលខ្លះ ឌុច ក៏បានចូលរួមធ្វើដោយផ្ទាល់ដែរ ជាពិសេសជាមួយក្រុមធ្វើទារុណកម្មសួរចម្លើយ។

ក្នុងមន្ទីរ១៣ ឌុច បែងចែកអ្នកជាប់ឃុំជា២ប្រភេទ គឺអ្នកជាប់ឃុំកម្រិតស្រាល និងអ្នកជាប់ឃុំកម្រិតធ្ងន់។ ក្រុមទាំងពីរនេះ មានស្ថានភាពជាប់ឃុំខុសគ្នាដ្បិតអ្នកជាប់ឃុំកម្រិតស្រាលអាចចេញធ្វើការនៅពេលថ្ងៃ ប៉ុន្តែអ្នកជាប់ឃុំកម្រិតធ្ងន់ត្រូវជាប់ឃុំរហូត។ យ៉ាងណាមិញ ចំពោះការកំណត់ថាមនុស្សមានប្រវត្តិរូបបែបណានឹងក្លាយជាអ្នកជាប់ឃុំកម្រិតស្រាល ឬកម្រិតធ្ងន់នោះ យើងពិបាកធ្វើការបែងចែកណាស់ ដ្បិតមានជនរងគ្រោះខ្លះត្រូវចាប់ចូលមន្ទីរឃុំឃាំងទាំងគ្រួសារ ប៉ុន្តែមានជាប់ជាអ្នកជាប់ឃុំកម្រិតស្រាល និងជាអ្នកជាប់ឃុំកម្រិតធ្ងន់។ មូលហេតុនៃការចាប់ខ្លួន ខ្មែរក្រហមបានប្រើហេតុផលជារួមមួយ គឺ ចោទថាជា "**គិញ**" ដែលពាក្យគិញនេះ ហាក់មានន័យទូលំទូលាយ ដ្បិតអ្នកមានប្រវត្តិរូបបែបណាក៏ថាជាគិញដែរ។ អតីតរដ្ឋការក្នុងសម័យសង្គមរាស្ត្រនិយម សាធារណរដ្ឋខ្មែរ អ្នកដែលបានធ្វើដំណើរឆ្លងកាត់ព្រំប្រទល់ រវាងតំបន់រំដោះ និងតំបន់គ្រប់គ្រងដោយទាហានលន់ នល់ និងប្រជាជនមូលដ្ឋានសុទ្ធសឹងតែអាច ចាត់ចូលជាគិញ។ ពេលខ្លះឲ្យតែមានការទម្លាក់គ្រាប់បែកនៅតំបន់ណា តែងមានការចាប់ខ្លួននៅតំបន់នោះ ដោយចោទថាមានគិញឲ្យដំណឹងទៅខាងទាហានលន់ នល់។ ចំនួនអ្នកជាប់ឃុំ យើងមិនឃើញមានរបាយការណ៍ណាមួយបញ្ជាក់ឲ្យបានច្បាស់លាស់នោះទេ។

ទម្រង់នៃការបង្កើតមន្ទីរសន្តិសុខនេះ បានក្លាយជាទម្រង់មួយដែលខ្មែរក្រហមយកទៅអនុវត្តបន្តទៀតនៅអំឡុងពេលកាន់អំណាចពេញលេញ ដោយបានបង្កើតជាមន្ទីរសន្តិសុខនៅទូទាំងប្រទេស ដើម្បីស្វែងរក និងសម្លាប់ជនទាំងឡាយណាដែលខ្លួនចោទថាជាខ្មាំងបដិវត្តន៍។

# ចំណាប់អារម្មណ៍




**កែវ ដួង៖** ខ្ញុំសប្បាយចិត្ត និងមានមោនភាពខ្លាំងណាស់ចំពោះការចូលរួមរបស់ខ្ញុំផ្ទាល់ជាមួយគម្រោងស្រាវជ្រាវនេះក្នុងនាមជា គ្រូដឹកនាំការធ្វើការជាមួយបុគ្គលិកសារមន្ទីរ និងប្អូនៗនិស្សិតទាំង៦រូប។ ចំណុចសំខាន់ៗដែលលើកទឹកចិត្តឲ្យខ្ញុំចូលរួមជាមួយគម្រោងស្រាវជ្រាវនេះគឺ ខ្ញុំបានរួមចំណែកក្នុងការការបណ្តុះបណ្តាលអ្នកស្រាវជ្រាវវ័យក្មេង ការគាំទ្រកិច្ចការស្រាវជ្រាវដើម្បីសម្រេចលទ្ធផល បង្កើតចំណេះដឹងថ្មី និងការចូលរួមផ្តល់ប្រយោជន៍ដល់សង្គមជាតិ។ ទីមួយ គម្រោងនេះបានផ្តល់ឱកាសដល់និស្សិតប្រវត្តិវិទ្យាបីរូប និងនិស្សិតបុរាណវិទ្យាបីរូប ដើម្បីទទួលបានការបណ្តុះបណ្តាលខ្លីពីមូលដ្ឋានគ្រឹះនៃការស្រាវជ្រាវលើប្រធានបទ មុននឹងចុះស្រាវជ្រាវផ្ទាល់លើប្រធានបទ **“មន្ទីរ១៣(ម-១៣)៖ មន្ទីរសន្តិសុខខ្មែរក្រហមក្នុងសម័យសង្គ្រាម (១៩៧០-១៩៧៥)”**។ តាមរយៈការបណ្តុះបណ្តាល និងការសិក្សាស្រាវជ្រាវនេះ និស្សិតទាំង៦រូបទទួលបានចំណេះដឹងក្នុងការស្រាវជ្រាវ ក៏ដូចជាចំណេះដឹងលើប្រធានបទនេះ។ ទីពីរ ការសម្រេចបាននូវការបោះពុម្ពផ្សាយនេះនឹងផ្តល់ជូនអ្នកអាននូវចំណេះដឹងថ្មី បន្ថែមលើការសិក្សាស្រាវជ្រាវមុនៗ ដែលជាប្រយោជន៍សម្រាប់អ្នកអាន ក៏ដូចជាអ្នកសិក្សាស្រាវជ្រាវផ្សេងៗ។ ទីបី លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះក៏មានតម្លៃសម្រាប់សារមន្ទីរទួលស្លែង ក៏ដូចជាក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីជាមូលដ្ឋានក្នុងការកែប្រែអតីតមន្ទីរម១៣នេះទៅជាសារមន្ទីរនៃការចងចាំនាថ្ងៃអនាគត។ ខ្ញុំសង្ឃឹមថា គម្រោងបែបនេះនឹងមានជាបន្តបន្ទាប់សម្រាប់ការស្រាវជ្រាវលើប្រធានបទជាច្រើនបន្ថែមទៀត។



កញ្ញា **អូត ស្រីពេជ្រ៖** សម្រាប់នាងខ្ញុំគម្រោងនេះពិតជាមានតម្លៃណាស់ ព្រោះបានផ្តល់នូវចំណេះដឹងជាច្រើន ជាពិសេសសារតារបស់ខ្មែរក្រហម ដែលបានកើតឡើងនៅចុងទសវត្សរ៍៦០ មានទីតាំងយុទ្ធសាស្ត្រស្ថិតនៅទឹកដីខេត្តកំពង់ស្ពឺ។ លើសពីនេះ ចំណេះដឹងអំពីមន្ទីរ១៣ ដែលខ្មែរក្រហមបង្កើតឡើងនៅឃុំអមលាំង ដើម្បីឃុំឃាំងមនុស្ស និងជាទីកន្លែង សម្រាប់ពិសោធនូវទារុណកម្មរបស់ខ្លួន រហូតឈានដល់ការសម្លាប់មនុស្សទៀតផង។ ដូច្នេះ ទិន្នន័យនេះអាចបង្ហាញអំពីឥរិយាបទរបស់ខ្មែរក្រហមមុនការកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មួយចំណែកផងដែរ។ ក្រៅពីនេះក៏បានផ្តល់នូវបទពិសោធន៍ និងជួបមនុស្សជាច្រើន ដែលធ្វើឲ្យខ្ញុំរៀនបន្ថែមលើជំនាញរបស់ខ្ញុំ ដើម្បីអភិវឌ្ឍន៍ខ្លួននៅពេលអនាគត។ ជាចុងក្រោយ ខ្ញុំពិតជារីករាយណាស់ក្នុងការចូលរួមជាផ្នែកមួយក្នុងគម្រោងនេះ។



លោក **លន់ ចន្ថា៖** បន្ទាប់ពីបានចូលរួមគម្រោងស្រាវជ្រាវអំពីប្រវត្តិម-១៣ ខ្ញុំពិតជាទទួលបានចំណេះដឹងថ្មីៗនិងបទពិសោធន៍ថ្មីៗជាច្រើនដូចជាវិធីសាស្ត្រស្រាវជ្រាវ ការសម្ភាសន៍ ការចងក្រងជាឯកសារ និងរបៀបដាក់ឯកសារយោងជាដើម។ ការស្រាវជ្រាវនេះបានធ្វើឲ្យខ្ញុំយល់ដឹងបន្ថែមពីព្រឹត្តិការណ៍នាចុងទស្សវត្សរ៍៦០ និងដើមទសវត្សរ៍៧០ ក្នុងទឹកដីតំបន់អមលាំង។ ខ្ញុំអាចយល់ដឹងអំពីភាពខុសគ្នានៃគោលនយោបាយខ្មែរក្រហមមុន និងអំឡុងពេលកាន់អំណាច។ ជាពិសេសការបង្កើតគុកម-១៣ (ឬត្រពាំងប្រាប) របស់ខ្មែរក្រហម រួមផ្សំទាំងគោលនយោបាយរបស់ខ្មែរក្រហមនិងវិធីសាស្ត្រនៃការគ្រប់គ្រងអ្នកទោស ព្រមទាំងទិដ្ឋភាពទូទៅនៅទីនោះ។ យ៉ាងណាក៏ដោយ វាក៏មានផលវិបាកខ្លះដែរ ក្នុងការស្វែងរកប្រជាជនសម្ភាសន៍ ជាពិសេសទិន្នន័យដែលពួកយើងចង់បាន។ តែផ្ទុយមកវិញ ប្រធានបទមួយនេះពួកយើងនៅតែអាចព្យាយាមសម្រេចបានជាផ្លែផ្កា។



កញ្ញា **រី ក្រវ៉ាន់៖** ចំពោះខ្ញុំគម្រោងស្រាវជ្រាវពីប្រវត្តិម-១៣នេះ មានសារៈសំខាន់ខ្លាំងណាស់ គឺទទួលបាននូវចំណេះដឹង បទពិសោធន៍និងចងក្រងជាឯកសារដល់សាធារណៈជនទូទៅ ដែលចង់សិក្សាស្វែងយល់។ ប្រជាពលរដ្ឋខ្មែរតិចតួចណាស់ ដែលស្គាល់មន្ទីរ១៣ ឬគុកតាឌុច ដែលភាគច្រើនពួកគាត់ស្គាល់ តែគុកទួលស្លែងប៉ុណ្ណោះ។ គម្រោងស្រាវជ្រាវមួយនេះបានផ្សារ ភ្ជាប់ទំនាក់ទំនងអំពីរបៀបធ្វើការងារ ការថែរក្សាអភិរក្ស និងការ ផ្សព្វផ្សាយផ្សះផ្សាផ្លូវចិត្តដល់ប្រជាពលរដ្ឋដែលមានសាច់ញាតិ បាត់បង់ជីវិតក្រោមការដឹកនាំដោយខ្មែរក្រហម។ អ្វីដែលខ្ញុំរំពឹងទុកពីការងារស្មគ្រចិត្តនេះ គឺដើម្បីចូលរួម ចំណែកចងក្រងឯកសារប្រវត្តិសាស្ត្រសម្រាប់យុវជនជំនាន់ក្រោយអោយបានដឹង និងជៀសវាងកុំឲ្យដើរ ជាន់ដានប្រវត្តិសាស្ត្រ។



លោក **ងៅ មេសា៖** ឱកាសនៃការចូលរួម ការស្រាវជ្រាវអំពីប្រវត្តិមន្ទីរ១៣ នៅឃុំ អមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ជាបទ ពិសោធន៍ការងារដ៏ល្អមួយសម្រាប់ខ្ញុំ។ គម្រោងនេះ បានផ្តល់នូវបទពិសោធន៍ ការចុះសម្ភាសន៍ប្រជាជន បន្ថែមចំណេះដឹង ប្រវត្តិសាស្ត្រខ្មែរក្រហម បានស្គាល់នូវទីតាំង ភូមិសាស្ត្រតំបន់អមលាំង ពិសេសមន្ទីរ១៣ ដែលបានសម្លាប់មនុស្សអស់ជាច្រើន។ គម្រោងនេះនឹងបង្ហាញពីទិដ្ឋភាពប្រវត្តិមន្ទីរ១៣ ក៏ដូចតំបន់អមលាំង ឲ្យអ្នកជំនាន់ក្រោយបានដឹង។ ជាចុងក្រោយខ្ញុំពិតជាមានភាពសប្បាយរីករាយណាស់ដែលបានចូលក្នុង ការងារមួយនេះហើយខ្ញុំសង្ឃឹមថាគម្រោងនេះ នឹងផ្តល់នូវគុណប្រយោជន៍សម្រាប់ប្រទេសជាតិក្នុងជ្រុង ណាមួយពុំខានឡើយ។



លោក **អ៊ុក វណ្ណារិទ្ធិ**៖ គម្រោងស្រាវជ្រាវអំពីប្រវត្តិមន្ទីរ១៣ បានផ្តល់នូវការយល់ដឹងកាន់តែស៊ីជម្រៅអំពីតថភាពនៃមន្ទីរសន្តិសុខខ្មែរក្រហមនៅមុនពេលទទួលបានជ័យជំនះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ គម្រោងស្រាវជ្រាវនេះ ក៏បានផ្តល់ចំណេះដឹងថ្មីៗអំពីវិធីសាស្រ្តស្រាវជ្រាវ ដូចជាការស្វែងរកប្រមូលឯកសារ និងការចុះសម្ភាសន៍ប្រជាជនផ្ទាល់។ ខ្ញុំជឿជាក់ថាគម្រោងស្រាវជ្រាវនេះមុខជាមានប្រយោជន៍ពុំលែងឡើយ តាមរយៈការបោះពុម្ពផ្សាយលទ្ធផលនៃការស្រាវជ្រាវដល់សាធារណៈជន ដែលចាប់អារម្មណ៍ពីខ្មែរក្រហម។ បន្ថែមពីនេះ វាជាឯកសារដ៏សំខាន់មួយ ដែលគប្បីសិក្សាចងក្រងឲ្យហើយមុននឹងមនុស្សដែលឆ្លងកាត់ព្រឹត្តិការណ៍នោះបាត់បង់ទៅ ដោយពុំបានរៀបរាប់ពីបទពិសោធន៍នៃជីវិតរបស់ខ្លួនដល់អ្នកជំនាន់ក្រោយឲ្យបានដឹង ព្រមទាំងជាគំរូមួយដែលត្រូវចៀសវាងជាន់ដានប្រវត្តិសាស្រ្តឡើងវិញនៅថ្ងៃអនាគត។

លោក **ជិត ច័ន្ទភក្តី**៖ ជាដំបូងសូមអរគុណដល់សារមន្ទីរទួលស្លែង ដែលបានបង្កើតគម្រោងស្រាវជ្រាវអំពីម-១៣។ ខ្ញុំមានសេចក្តីរីករាយ ដែលបានចូលរួមស្រាវជ្រាវ និងទទួលបាននូវចំណេះដឹងថ្មីៗជាច្រើន។ ជាចុងក្រោយសូមជូនពរដល់ក្រុមស្រាវជ្រាវឲ្យជួបតែសំណាងល្អ។



# សេចក្ដីថ្លែងអំណរគុណ

លទ្ធផលនៃការស្រាវជ្រាវនេះ នឹងមិនអាចកើតមានបានឡើយប្រសិនបើគ្មានការគាំទ្រពី៖

- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែ ប្រចាំប្រទេសកម្ពុជា ( Konrad-Adenauer-Stiftung Cambodia ) ដែលបានគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ការងារស្រាវជ្រាវ
- សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និង សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ដែលបានអនុញ្ញាតឲ្យនិស្សិតបានចូលរួមជាសមាជិកក្រុមស្រាវជ្រាវ
- លោក កែវ ដួង គ្រូឧទ្ទេសផ្នែកប្រវត្តិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- លោក សាឃឿន សក្ដា គ្រប់គ្រងថ្នាក់ជាតិនៃអង្គការមូលនិធិបុរាណវិទ្យា និងអភិវឌ្ឍន៍( AFP)
- ប្រជាជន និងអាជ្ញាធរមូលដ្ឋានក្នុងស្រុកថ្ពង ខេត្តកំពង់ស្ពឺដែលបានចំណាយពេលវេលាដ៏មានតម្លៃឲ្យក្រុមស្រាវជ្រាវជួបសម្ភាសន៍៖
    - លោក សួង ពៅ មេភូមិត្រាញ់វែង
    - លោកស្រី ខួច គេច
    - លោកស្រី សិន នួន
    - លោក ជុំ ជួន
    - លោក ចាន់ រឿន
    - លោក ដួង ណិន
    - លោក សៅ វ៉ន
    - លោក ស្រី ជឿន
    - លោកស្រី ខាំ សុខុម
    - លោក កៅ យឹម
    - លោកស្រី អ៊ឹម សាំង
    - លោកស្រី ហ៊ិន នៅ
    - លោក ព្រំ វង់
    - លោកស្រី ស ផល្លា
    - លោក ស សារិន (ហៅ តឿង អូន)
    - លោក ម៉ែន ហេន

របាយការណ៍ស្រាវជ្រាវ

# មន្ទីរ១៣ (ម-១៣)៖ មន្ទីរសន្តិសុខខ្មែរក្រហមក្នុងសម័យសង្គ្រាម(១៩៧០-១៩៧៥)

## ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែ ប្រចាំប្រទេសកម្ពុជា(Konrad-Adenauer-Stiftung Cambodia)

## ក្រុមការងារស្រាវជ្រាវ/សម្ភាសន៍/សរសេរអត្ថបទ៖

ហង្ស និស្ស័យ (សារមន្ទីរ)

រឿន វណ្ណដេត (សារមន្ទីរ)

សុង ភក្ត្រា (សារមន្ទីរ)

វង្ស សំអេង (សារមន្ទីរ)

អ៊ូត ស្រីពេជ្រ (និស្សិតប្រវត្តិវិទ្យា)

លន់ ចន្ថា (និស្សិតប្រវត្តិវិទ្យា)

រី ក្រវ៉ាន់ (និស្សិតប្រវត្តិវិទ្យា)

ងៅ មេសា (និស្សិតបុរាណវិទ្យា)

អ៊ុក វណ្ណារិទ្ធិ (និស្សិតបុរាណវិទ្យា)

ជិត ច័ន្ទភក្រ្តី (និស្សិតបុរាណវិទ្យា)

## រចនាដោយ៖

ហួត សារ៉ាត់

ហេង សុផារ៉ា

## ពិនិត្យ និងកែសម្រួលអត្ថបទ

ហង្ស និស្ស័យ

កែវ ដួង

រឿន វណ្ណដេត

សុង ភក្ត្រា

# កំណត់ចំណាំ


១. Pong-Rasy, P. (November 7, 2006). DK Prison. DC-Cam
២. សូមមើលលិខិតលេខ CLT/WHC/NOM/20/124 ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២០របស់គណៈកម្មធិការវប្បធម៌នៃអង្គការយូណេស្កូ ស្តីពីការបញ្ចូលទីតាំងបន្ថែមទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកបណ្តោះអាសន្ន ក្នុងនោះរួមមានទីតាំងប្រវត្តិសាស្ត្រដូចជា អតីតមន្ទីរឃុំឃាំងម-១៣ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង(អតីតមន្ទីរស-២១) និងមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក (អតីតកន្លែងពិឃាតរបស់ស-២១)
៣. ខ្មែរក្រហមទទួលស្គាល់តំបន់នានានៃខេត្តកំពង់ស្ពឺ ជាពិសេសតំបន់ជុំវិញអមលាំងជាមូលដ្ឋានតស៊ូដំបូងៗរបស់ខ្លួន។ សូមមើល ក្រសួងសិក្សាធិការ. (១៩៧៧). ភូមិសាស្ត្រកម្ពុជាប្រជាធិបេតយ្យៈផ្នែកនយោបាយ ថ្នាក់ទី២. បោះពុម្ពលើកទី១.ទំ.១៤-១៥ (NBK_0005_d001)
៤. ព្រុំ វង្ស. (១៥ តុលា ២០២០). ប្រវត្តិមន្ទីរម-១៣. (អ្នកសម្ភាសន៍. លន់ ចន្ថា) កំពង់ស្ពឺ.
៥. អ៊ឹម សាំង. (០២ តុលា ២០២០). ប្រវត្តិមន្ទីរម.១៣. (អ្នកសម្ភាសន៍. រឿន វណ្ណដេត) កំពង់ស្ពឺ
៦. Justin Corfield. (1994). ខ្មែរក្រោក. (បកប្រែ. វង់ សុជាវ៉ា និងណុប សុខា) ភ្នំពេញ ទំព័រ១១៦-១១៨
៧. កៅ យឹម. (០២ តុលា ២០២០). ប្រវត្តិមន្ទីរម-១៣. (អ្នកសម្ភាសន៍. អ៊ូត ស្រីពេជ្រ). កំពង់ស្ពឺ
៨. François Bizot. (2009). Le Silence du Bourreau, p.183.
៩. ណាយ៉ាន់ ចាន់ដា. (២០០៦). សត្រូវបងប្អូនឯង. (បកប្រែ. ទេព ម៉េងឃាន) ភ្នំពេញៈ មជ្ឈមណ្ឌលឯកសារកម្ពុជា. ទំព័រ៧៣-៧៤
១០. ប្រតិចារឹក«ឌុច»៖ ស្តីពីការបង្កើតម-១៣ ឯកសារលេខ E1_8.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា). (០៦ មេសា ២០០៩). ទំព័រ៥២-៥៣
១១.ប្រតិចារឹក«ឌុច»៖ ស្តីពីការបង្កើតម-១៣ ឯកសារលេខ E1_8.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា). (០៦ មេសា ២០០៩). ទំព័រ៥៥
១២. ប្រតិចារឹក«ឌុច»៖ ស្តីពីការបង្កើតម-១៣ ឯកសារលេខ E1_8.1_KH_0 (០៦ មេសា ២០០៩). ទំព័រ៥៣-៥៤
១៣. ប្រតិចារឹក«ឌុច»៖ ស្តីពីការបង្កើតម-១៣ ឯកសារលេខ E1_8.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា). (០៦ មេសា ២០០៩) ទំព័រ៥០-៥១
១៤. François Bizot. (2009). Le Silence du Bourreau. P. 183
១៥. ប្រតិចារឹក៖ ស្តីពីការបង្កើតម-១៣ ឯកសារលេខ E1_9.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា). (០៧ មេសា ២០០៩). ទំព័រ៤៥-៤៦
១៦. ផេង ពង្សរ៉ាស៊ី. (មិថុនា-២០០៣). ប្រព័ន្ធសន្តិសុខភូមិភាគពិសេសម-១៣:ទស្សនាវដ្តីស្វែងរកការពិត (លេខ៤២)
១៧. ប្រតិចារឹក៖ ស្តីពីការបង្កើតម-១៣ឯកសារលេខ E1_8.1_KH (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា). (៦ មេសា ២០០៩). ទំព័រ៥១-៥២
១៨. ប្រតិចារឹក៖ ស្តីពីការបង្កើតម-១៣  ឯកសារលេខ E1_6.1_KH (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា). (៣១ មីនា ២០០៩). ទំព័រ៤៧-៤៨
១៩. ប្រតិចារឹក«ឌុច»៖ ស្តីពីការបង្កើតម-១៣ ឯកសារលេខ E1_10.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា). (០៨ មេសា ២០០៩). ទំព័រ២
២០. ដួង ណិន. (០១ តុលា ២០២០). ប្រវត្តិមន្ទីរម-១៣. (អ្នកសម្ភាសន៍លើកទី១ ង៉ៅ មេសា) និង ដួន ណិន. (១៥ តុលា ២០២០). ប្រវត្តិមន្ទីរម-១៣ (អ្នកសម្ភាសន៍លើកទី២ រឿន វណ្ណដេត). កំពង់ស្ពឺ.

២១. ប្រតិចារឹក«ឌុច»៖ ស្តីពីការបង្កើតម-១៣ ឯកសារលេខ E1_8.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា). (៧ មេសា ២០០៩). ទំព័រ៥៨-៥៩
២២. សោម ប៊ុនថន. ( មិថុនា ២០០៩). ចម្លើយសារភាពរបស់ឌុចទាក់ទងនឹងមន្ទីម.១៣. ទស្សនាវដ្តីស្វែងរកការពិត, ១១៤.
២៣. ប្រតិចារឹក«ឌុច» ៖ ស្តីពីការបង្កើតម-១៣ឯកសារលេខ E1_8.1_KH (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា). (៦ មេសា ២០០៩). ទំព័រ៥៧
២៤. ដួង ណិន. (០១-តុលា-២០២០). ប្រវត្តិមន្ទីរម-១៣. (អ្នកសម្ភាសន៍លើកទី១ ងៅ មេសា) និង ខាំ សុខុម. (០២-តុលា- ២០២០) ប្រវត្តិមន្ទីរម-១៣ (អ្នកសម្ភាសន៍ អួត ស្រីពេជ្រ). កំពង់ស្ពឺ.
២៥. ប្រតិចារឹក«ឌុច»៖ ស្តីពីការបង្កើតម-១៣ ឯកសារលេខ E1_8.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា). (០៧ មេសា ២០០៩). ទំព័រ៥៨-៥៩
២៦. ដួង ណិន (០១ តុលា ២០២០). ប្រវត្តិមន្ទីរម-១៣. (អ្នកសម្ភាសន៍លើកទី១ ងៅ មេសា) និង ដួន ណិន. (១៥ តុលា ២០២០). ប្រវត្តិមន្ទីរម-១៣ (អ្នកសម្ភាសន៍លើកទី២ រឿន វណ្ណដេត) កំពង់ស្ពឺ.
២៧. ដួង ណិន (០១ តុលា ២០២០). ប្រវត្តិមន្ទីរម-១៣. (អ្នកសម្ភាសន៍លើកទី១ ងៅ មេសា) និង ដួន ណិន. (១៥ តុលា ២០២០). ប្រវត្តិមន្ទីរម-១៣ (អ្នកសម្ភាសន៍លើកទី២ រឿន វណ្ណដេត) កំពង់ស្ពឺ.
២៨. ប្រតិចារឹក«ឌុច»៖ ស្តីពីការបង្កើតម-១៣ ឯកសារលេខ E1_8.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា). (០៦ មេសា ២០០៩). ទំព័រ៥៧-៥៩
២៩. ដួង ណិន (០១ តុលា ២០២០). ប្រវត្តិមន្ទីរម-១៣. (អ្នកសម្ភាសន៍លើកទី១ ងៅ មេសា) និង ខាំ សុខុម (០២ តុលា ២០២០) ប្រវត្តិមន្ទីរម-១៣ (អ្នកសម្ភាសន៍ អួត ស្រីពេជ្រ) កពង់ស្ពឺ.
៣០. ហ៊ិន នៅ. (១៤ តុលា ២០២០). ប្រវត្តិមន្ទីរម-១៣. (អ្នកសម្ភាសន៍ លន់ ចន្ថា) កំពង់ស្ពឺ.
៣១. សោម ប៊ុនថន. ( មិថុនា ២០០៩). ចម្លើយសារភាពរបស់ឌុចទាក់ទងនឹងមន្ទីម.១៣. ទស្សនាវដ្តីស្វែងរកការពិត, ១១៤.
៣២. ហ៊ិន នៅ. (១៤ តុលា ២០២០). ប្រវត្តិមន្ទីរម-១៣. (អ្នកសម្ភាសន៍ លន់ ចន្ថា) កំពង់ស្ពឺ.
៣៣. ដួង ណិន (០១ តុលា ២០២០). ប្រវត្តិមន្ទីរម-១៣. (អ្នកសម្ភាសន៍លើកទី១ ងៅ មេសា) និង ដួន ណិន. (១៥ តុលា ២០២០). ប្រវត្តិមន្ទីរម-១៣ (អ្នកសម្ភាសន៍លើកទី២ រឿន វណ្ណដេត) កំពង់ស្ពឺ.
៣៤. សោម ប៊ុនថន. (មិថុនា ២០០៩). ចម្លើយរបស់ឌុច ទាក់ទងនឹងមន្ទីរម-១៣: ទស្សនាវដ្តីស្វែងរកការពិត (លេខ១១៤).
៣៥. ស្រី ជឿន. (០១ តុលា ២០២០) ប្រវត្តិមន្ទីរម-១៣ (អ្នកសម្ភាសន៍ រី ក្រវ៉ាន់) កំពង់ស្ពឺ.
៣៦. ប្រតិចារិក៖ ស្តីពីការបង្កើតម-១៣ ឯកសារលេខ E1_8.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា). (៦ មេសា ២០០៩). ទំព័រ១៦-២០.
៣៧. ប្រតិចារិក៖ស្តីពីការបង្កើតម-១៣ ឯកសារលេខ E1_10.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា). (៨ មេសា ២០០៩). ទំព័រ២០.
៣៨. ផេង ពង្សរ៉ាស៊ី. (មិថុនា ២០០៣). ប្រព័ន្ធសន្តិសុខភូមិភាគពិសេសម.១៣. ទស្សនាវដ្តីស្វែងរកការពិត, លេខ៤២, ទំព័រ១៧.
៣៩. ព្រំ វង្ស. (១៥ តុលា ២០២០) ប្រវត្តិមន្ទីរម-១៣(អ្នកសម្ភាសន៍. លន់ ចន្ថា) កំពង់ស្ពឺ.
៤០. ប្រតិចារិក៖ ស្តីពីការបង្កើតម-១៣, ឯកសារលេខ E1_9.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា). (០៧ មេសា ២០០៩). ទំព័រ២០.

៤១. ប្រតិចារិក៖ ស្តីពីការបង្កើតម-១៣ ឯកសារលេខ E1_9.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា).
(០៧ មេសា ២០០៩). ទំព័រ.២០.
៤២. ចាន់ រឿន. (០១ តុលា ២០២០). ប្រវត្តិមន្ទីរម-១៣. (អ្នកសម្ភាសន៍. អ៊ុក វណ្ណារិទ្ធ, ងៅ មេសា, អូត ស្រីពេជ្រ) កំពង់ស្ពឺ.
៤៣. ប្រតិចារិក៖ ស្តីពីការបង្កើតម-១៣ ឯកសារ E1_9.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា).
(០៧ មេសា ២០០៩). ទំព័រ២០.
៤៤. សោម ប៊ុនថន. ( មិថុនា ២០០៩). ចម្លើយសារភាពរបស់ឌុចទាក់ទងនឹងមន្ទីរម.១៣. ទស្សនាវដ្តីស្វែងរកការពិត, ១១៤, ទំព័រ៦.
៤៥. ចាន់ រឿន. (០១ តុលា ២០២០). ប្រវត្តិមន្ទីរម-១៣. (អ្នកសម្ភាសន៍. អ៊ុក វណ្ណារិទ្ធ, ងៅ មេសា, អូត ស្រីពេជ្រ) កំពង់ស្ពឺ.
៤៦. ដួង ណិន (០១ តុលា ២០២០). ប្រវត្តិមន្ទីរម-១៣. (អ្នកសម្ភាសន៍លើកទី១ ងៅ មេសា) និង ដួន ណិន.
(១៥ តុលា ២០២០). ប្រវត្តិមន្ទីរម-១៣ (អ្នកសម្ភាសន៍លើកទី២ រឿន វណ្ណដេត) កំពង់ស្ពឺ.
៤៧. នីក ដុនឡុប. (២០០៦). ពេជ្ឈឃាតបាត់ខ្លួន. (បកប្រែ. ហេង ហាំងខេង) ភ្នំពេញ: បណ្ណាគារអង្គរ. ទំព័រ ៧៥.
៤៨. ផេង ពង្សរ៉ាស៊ី. ( មិថុនា ២០០៣). ប្រព័ន្ធសន្តិសុខភូមិភាគពិសេសម.១៣. ទស្សនាវដ្តីស្វែងរកការពិត, លេខ៤២, ទំព័រ. ១៨
៤៩. នីក ដុនឡុប. (២០០៦). ពេជ្ឈឃាតបាត់ខ្លួន. (បកប្រែ. ហេង ហាំងខេង) ភ្នំពេញ: បណ្ណាគារអង្គរ. ទំព័រ. ៧៥.
៥០. ផេង ពង្សរ៉ាស៊ី. ( មិថុនា ២០០៣). ប្រព័ន្ធសន្តិសុខភូមិភាគពិសេសម.១៣. ទស្សនាវដ្តីស្វែងរកការពិត, លេខ៤២, ទំព័រ១៨.
៥១. អ្នកស្រុកហៅថា ស្ទឹងជ្រាវ
៥២. ចាន់ រឿន. (០៦ មីនា ២០១៩). ប្រវត្តិមន្ទីរម-១៣. (អ្នកសម្ភាសន៍. ហង្ស និស្ស័យ) កំពង់ស្ពឺ.
៥៣. ប្រតិចារិក៖ ស្តីពីការបង្កើតម-១៣ ឯកសារលេខ E1_12.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា).
(២០ មេសា ២០០៩).ទំព័រ.៦៣-៦៥.
៥៤. ចាន់ រឿន. (០១ តុលា ២០២០). ប្រវត្តិមន្ទីរម-១៣. (អ្នកសម្ភាសន៍. អ៊ុក វណ្ណារិទ្ធ, ងៅ មេសា, អូត ស្រីពេជ្រ) កំពង់ស្ពឺ.
៥៥. ផេង ពង្សរ៉ាស៊ី. ( មិថុនា ២០០៣). ប្រព័ន្ធសន្តិសុខភូមិភាគពិសេសម.១៣. ទស្សនាវដ្តីស្វែងរកការពិត, លេខ៤២, ទំព័រ. ១៨.
៥៦. ប្រតិចារិក៖ ស្តីពីការបង្កើតម-១៣ ឯកសារលេខ E1_9.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា).
(០៧ មេសា ២០០៩).ទំព័រ.២៣.
៥៧. អឹម សាំង. (០២ តុលា ២០២០). ប្រវត្តិមន្ទីរម.១៣. (អ្នកសម្ភាសន៍. រឿន វណ្ណដេត) កំពង់ស្ពឺ.
៥៨. ចាន់ រឿន. (០១ តុលា ២០២០). ប្រវត្តិមន្ទីរម-១៣. (អ្នកសម្ភាសន៍.  ងៅ មេសា) កំពង់ស្ពឺ.
៥៩. ស សារិន ហៅ តឿង អូន. (១៦ តុលា ២០២០). ប្រវត្តិមន្ទីរម-១៣. (អ្នកសម្ភាសន៍. ហង្ស និស្ស័យ) កំពង់ស្ពឺ.
៦០. នីក ដុនឡុប. (២០០៦). ពេជ្ឈឃាតបាត់ខ្លួន. (បកប្រែ. ហេង ហាំងខេង) ភ្នំពេញ: បណ្ណាគារអង្គរ, ទំព័រ. ៧៤.
៦១. ប្រតិចារិក៖ស្តី ពីការបង្កើតម-១៣ ឯកសារលេខ E1_9.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា).
(០៧ មេសា ២០០៩). ទំព័រ.៤
៦២. ប្រតិចារិក៖ ស្តីពីការបង្កើតម-១៣ ឯកសារលេខ E1_9.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា).
(០៧ មេសា ២០០៩). ទំព័រ ៤-៩.
៦៣. ប្រតិចារិក៖ ស្តីពីការបង្កើតម-១៣ ឯកសារលេខ E1_13.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា).
(២១ មេសា ២០០៩). ទំព័រ ៦១-៦២
៦៤. ប្រតិចារិក៖ ស្តីពីការបង្កើតម-១៣ ឯកសារលេខ E1_9.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា).
(០៧ មេសា ២០០៩). ទំព័រ ៥១-៥៣
៦៥. ដេវីឌ ឆាណ្ឌល័រ. (២០០៣). សំឡេងពីមន្ទីរស.២១: ភាពភ័យខ្លាច និងប្រវត្តិក្នុងគុកសម្ងាត់របស់ប៉ុល ពត. ភ្នំពេញ: មជ្ឈមណ្ឌលឯកសារកម្ពុជា.

៦៦. សោម ប៊ុនថន. ( មិថុនា ២០០៩). ចម្លើយសារភាពរបស់ឌុចទាក់ទងនឹងមន្ទីរ១៣. ទស្សនាវដ្តីស្វែងរកការពិត, ១១៤. ទំព័រ២
៦៧. ប្រតិចារិក៖ ស្តីពីការបង្កើតម-១៣, ឯកសារលេខ E1_11.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា).
(០៩ មេសា ២០០៩).ទំព័រ ៦០-៦៧
៦៨. ស សារិន ហៅ តឿង អួន (១៦ តុលា ២០២០). ប្រវត្តិមន្ទីរម-១៣. (អ្នកសម្ភាសន៍. ហង្ស និស្ស័យ) កំពង់ស្ពឺ.
៦៩. ជុំ ជួន. (៣០ កញ្ញា ២០២០).ប្រវត្តិមន្ទីរម-១៣.  (អ្នកសម្ភាសន៍. រី ក្រវ៉ាន់, លន់ ចន្ថា) កំពង់ស្ពឺ.
៧០. ហ៊ិន នៅ. (១៤ តុលា ២០២០). ប្រវត្តិមន្ទីរម-១៣. (អ្នកសម្ភាសន៍ លន់ ចន្ថា) កំពង់ស្ពឺ.
៧១. ប្រតិចារិក៖ ស្តីពីការបង្កើតម-១៣ ឯកសារលេខ E1_9.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា).
(០៧ មេសា ២០០៩). ទំព័រ១៣&៦៥
៧២. ប្រតិចារិក៖ ស្តីពីការបង្កើតម-១៣ ឯកសារលេខ E1_9.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា).
(០៧ មេសា ២០០៩). ទំព័រ២៣-២៤
៧៣. ប្រតិចារិក៖ ស្តីពីការបង្កើតម-១៣ ឯកសារលេខ E1_9.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា).
(០៧ មេសា ២០០៩). ទំព័រ១០, ៦៦, ៦៨
៧៤ ខាំ សុខុម. (០២ តុលា ២០២០). ប្រវត្តិមន្ទីរម.១៣. (អ្នកសម្ភាសន៍. រី ក្រវ៉ាន់) កំពង់ស្ពឺ.
៧៥. ផេង ពង្សរ៉ាស៊ី. ( មិថុនា ២០០៣). ប្រព័ន្ធសន្តិសុខភូមិភាគពិសេសម.១៣. ទស្សនាវដ្តីស្វែងរកការពិត, លេខ៤២,
៧៦. ប្រតិចារិក៖ ស្តីពីការបង្កើតម-១៣ ឯកសារលេខ E1_9.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា).
(០៧ មេសា ២០០៩).ទំព័រ ទំព័រ ២៤-២៦
៧៧. ផេង ពង្សរ៉ាស៊ី. ( មិថុនា ២០០៣). ប្រព័ន្ធសន្តិសុខភូមិភាគពិសេសម.១៣. ទស្សនាវដ្តីស្វែងរកការពិត, លេខ៤២,
៧៨. ស សារិន ហៅ តឿង អួន. (១៦ តុលា ២០២០). ប្រវត្តិមន្ទីរម-១៣. (អ្នកសម្ភាសន៍. ហង្ស និស្ស័យ) កំពង់ស្ពឺ.
៧៩. សោម ប៊ុនថន. ( មិថុនា ២០០៩). ចម្លើយសារភាពរបស់ឌុចទាក់ទងនឹងមន្ទីរ១៣. ទស្សនាវដ្តីស្វែងរកការពិត, ១១៤. ទំព័រ២-៨.
៨០. ស សារិន ហៅ តឿង អួន. (១៦ តុលា ២០២០). ប្រវត្តិមន្ទីរម-១៣. (អ្នកសម្ភាសន៍. ហង្ស និស្ស័យ) កំពង់ស្ពឺ.
៨១. ប៉េ អេស ជាអក្សរកាត់សម្គាល់លើក្រុមឆ្មាំគុកនាទសវត្សរ៍១៩៦០-១៩៧០។
៨២. ប្រតិចារិក៖ ស្តីពីការបង្កើតម-១៣ ឯកសារលេខ E1_9.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា).
(០៧ មេសា ២០០៩). ទំព័រ ៤៩-៥០
៨៣. ប្រតិចារិក៖ ស្តីពីការបង្កើតម-១៣ ឯកសារលេខ E1_9.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា).
(០៧ មេសា ២០០៩). ទំព័រ៩-១០
៨៤. ប្រតិចារិក៖ ស្តីពីការបង្កើតម-១៣ ឯកសារលេខ E1_9.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា).
(០៧ មេសា ២០០៩). ទំព័រ៣៤
៨៥. ប្រតិចារិក៖ ស្តីពីការបង្កើតម-១៣ ឯកសារលេខ E1_9.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា).
(០៧ មេសា ២០០៩). ទំព័រ១៩
៨៦. ប្រតិចារិក៖ ស្តីពីការបង្កើតម-១៣ ឯកសារលេខ E1_9.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា).
(០៧ មេសា ២០០៩). ទំព័រ២១
៨៧. សោម ប៊ុនថន. (មិថុនា ២០០៩). ចម្លើយសារភាពរបស់ឌុចទាក់ទងនឹងមន្ទីរ១៣. ទស្សនាវដ្តីស្វែងរកការពិត,១១៤, ទំព័រ២-៨.
៨៨. សោម ប៊ុនថន. (មិថុនា ២០០៩). ចម្លើយសារភាពរបស់ឌុចទាក់ទងនឹងមន្ទីរ១៣. ទស្សនាវដ្តីស្វែងរកការពិត, ១១៤, ទំព័រ១៦
៨៩. ផេង ពង្សរ៉ាស៊ី. (មិថុនា ២០០៣). ប្រព័ន្ធសន្តិសុខភូមិភាគពិសេសម.១៣. ទស្សនាវដ្តីស្វែងរកការពិត, លេខ៤២, ទំព័រ១៣-២១

៩០. ប្រតិចារិកៈ ស្តីពីការបង្កើតម-១៣ ឯកសារលេខ E1_9.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា). (០៧ មេសា ២០០៩). ទំព័រ៧, ១៤-១៥, ៤៨-៤៩
៩១. ស សារិន ហៅ គឿង អួន. (១៦ តុលា ២០២០). ប្រវត្តិមន្ទីរម-១៣. (អ្នកសម្ភាសន៍. ហង្ស និស្ស័យ) កំពង់ស្ពឺ.
៩២. ប្រតិចារិកៈ ស្តីពីការបង្កើតម-១៣ ឯកសារលេខ E1_9.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា). (០៧ មេសា ២០០៩). ទំព័រ៦៣
៩៣. ប្រតិចារិកៈ ស្តីពីការបង្កើតម-១៣ ឯកសារលេខ E1_9.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា). (០៧ មេសា ២០០៩).ទំព័រ ៥៩-៦០
៩៤. ស សារិន ហៅ គឿង អួន. (១៦ តុលា ២០២០). ប្រវត្តិមន្ទីរម-១៣. (អ្នកសម្ភាសន៍. ហង្ស និស្ស័យ) កំពង់ស្ពឺ.
៩៥. នីក ដុនឡុប. (២០០៦). ពេជ្ឈឃាតបាត់ខ្លួន. (បកប្រែ. ហេង ហាំងខេង) ភ្នំពេញ: បណ្ណាគារអង្គរ, ទំព័រ. ៧៦
៩៦. ប្រតិចារិកៈ ស្តីពីការបង្កើតម-១៣ ឯកសារលេខ E1_9.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា). (០៧ មេសា ២០០៩).ទំព័រ៤៦-៥០
៩៧. ស សារិន ហៅ គឿង អួន. (១៦ តុលា ២០២០). ប្រវត្តិមន្ទីរម-១៣. (អ្នកសម្ភាសន៍. ហង្ស និស្ស័យ) កំពង់ស្ពឺ.
៩៨. ប្រតិចារិកៈ ស្តីពីការបង្កើតម-១៣ ឯកសារលេខ E1_9.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា). (០៧ មេសា ២០០៩).ទំព័រ ៨-៩
៩៩. អ៊ឹម សាំង. (០២ តុលា ២០២០). ប្រវត្តិមន្ទីរម.១៣. (អ្នកសម្ភាសន៍. រឿន វណ្ណដេត) កំពង់ស្ពឺ.
១០០. ប្រតិចារិកៈ ស្តីពីការបង្កើតម-១៣, ឯកសារលេខ E1_12.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា). (២០ មេសា ២០០៩).ទំព័រ៩-១០
១០១. ស សារិន ហៅ គឿង អួន. (១៦ តុលា ២០២០). ប្រវត្តិមន្ទីរម-១៣. (អ្នកសម្ភាសន៍. ហង្ស និស្ស័យ) កំពង់ស្ពឺ.
១០២. ប្រតិចារិកៈ ស្តីពីការបង្កើតម-១៣ ឯកសារលេខ E1_9.1_KH_0 (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា). (០៧ មេសា ២០០៩).ទំព័រ ៨-៩, ៥៧